# ព្រះអភិធម្មក្នុងជីវិតប្រចាំថ្ងៃ

## ភាគ៣



រៀបរៀងដោយៈ
**ភិក្ខុ អគ្គចិត្តោ យ៉ុន យី**

ព.ស. ២៥៦៤

# មាតិកា


និយមន័យរូប ............................................ ០១

រូបមាន ៧ ន័យ............................................ ០២

សម្តែងរូបដោយន័យ ៥ .............................. ០៥

**រូបន័យទី១ រូបសមុទ្ទេស** ............................ ០៧

រូប ២៨ ចែកជា ២ ពួក................................. ០៩

មហាភូតរូបព្រោះហេតុ ៥ ........................... ១១

ភូតមាន ៧ ន័យ .......................................... ១២

បឋវីធាតុ ................................................... ១៥

បឋវីធាតុមាន ៤ យ៉ាង ................................ ១៦

អាបោធាតុ.................................................. ២០

អាបោធាតុ ៤ យ៉ាង ..................................... ២២

តេជោធាតុ.................................................. ២៥

តេជោធាតុ ៤ យ៉ាង ........................................ ២៦
វាយោធាតុ ........................................................ ២៨
វាយោធាតុមាន ៤ យ៉ាង ................................. ២៩
ពួកទី ២ បសាទរូប ៥ ...................................... ៣២
ចក្ខុបសាទរូប ................................................. ៣៣
ចក្ខុមាន ២ ប្រភេទ ......................................... ៣៥
បញ្ញាចក្ខុមាន ៥ .............................................. ៣៦
វេវចនរបស់ចក្ខុ ១៤ បទ ................................. ៣៨
សោតបសាទរូប ................................................. ៤០
សោតមាន ៣ យ៉ាង ........................................ ៤២
សោត ៧ ន័យ ................................................... ៤២
ឃានបសាទរូប ................................................. ៤៤
ជិវ្ហាបសាទរូប .................................................. ៤៥

កាយបសាទរូប .......................................... ៤៦
កាយ ៤ យ៉ាង .......................................... ៤៧
វិសយរូប ៧ .......................................... ៤៩
គន្ធៈ ៤ យ៉ាង .......................................... ៥២
រសមាន ៤ យ៉ាង.......................................... ៥៣
ភាវរូប ២ .......................................... ៥៥
ហទយរូប .......................................... ៥៨
ពណ៌ទឹកឈាមតាមចរិត ៦ .......................... ៥៨
ជីវិតរូប.......................................... ៦១
អាហាររូប .......................................... ៦២
បរិច្ឆេទរូប .......................................... ៦៣
អាកាស ៤ យ៉ាង..........................................៦៤
វិញ្ញត្តិរូប ២.......................................... ៦៥

វិការរូប.............................................. ៦៧
លក្ខណរូប ៤ ........................................ ៦៩
ជរាមាន ២ យ៉ាង ...................................៧២
**រូបន័យទី២ រូបវិភាគន័យ** ............................៧៣
ឯកវិធន័យ............................................ ៧៤
ទុកន័យ................................................. ៧៦
**រូបន័យទី៣ រូបសមុដ្ឋាន** ........................... ៨១
កម្មសមុដ្ឋាន ........................................... ៨២
ចិត្តសមុដ្ឋាន ..........................................៨៣
ចិត្តជរូបមាន ៧ ....................................... ៨៤
ឧតុសមុដ្ឋាន ........................................... ៨៨
អាហារសមុដ្ឋាន....................................... ៨៩
ប្រភេទហេតុនៃការកើតរូប ........................ ៩៤

ចែកកោដ្ឋាសរូប ៤២ តាមសមុដ្ឋានិករូប........ ៩៨
**រូបន័យទី៤ រូបកលាប** ............................ ១០៤
កលាបមានលក្ខណៈ ៤ យ៉ាង ................... ១០៤
កម្មជ្ជកលាប ៩ ....................................... ១០៦
កម្មជ្ជកលាបចែកជា ៣ ចំណែក................. ១០៩
ចិត្តជ្ជកលាប ៦ ....................................... ១១០
ឋានរបស់ចិត្តជ្ជកលាប ៦ ........................ ១១៥
ឧតុជ្ជកលាប ......................................... ១១៧
ឋានរបស់ឧតុជ្ជកលាប ៦......................... ១២០
ឧតុជ្ជកលាប ៤ យ៉ាង............................... ១២១
អាហារជ្ជកលាប ២................................. ១២២
កលាប ២១ ក្នុងអាការ ៤២ ..................... ១២៣
សសម្ភារបបវីមាន ២ ន័យ ...................... ១២៣

សសម្ភារអាបោ ១២ មាន ៣ ន័យ..............១២៥
សសម្ភារតេជោ ៤ មាន ២ ន័យ.................១២៦
សសម្ភារវាយោ ៦ មាន ២ ន័យ................ ១២៧
កលាបខាងក្នុងនិងខាងក្រៅ..................... ១៣០
**រូបន័យទី ៥ រូបបវត្តិក្កម**.......................... ១៣១
សម្តែងរូបដោយអាការៈ៣....................... ១៣៦
រូបកើតក្នុងភូមិ ២៧................................១៣៧
កាមភូមិ ១១ ដោយសមុដ្ឋាន ៤............... ១៣៩
ចែកសមុដ្ឋានិករូបពិស្តារ.........................១៤១
តាមន័យនៃកាលមាន ៣ កាល.................១៤៥
រូបដែលកើតក្នុងចុតិកាល....................... ១៤៧
សម្តែងរូប ២៨ ដោយកំណើត ៤ ..............១៤៩
ចែកកំណើត ៤ ដោយកម្មជកលាប ៩........ ១៥៣

ឱបបាតិកកំណើតជារូបព្រហ្ម(វៀរអសញ្ញី) .... ១៥៤
សម្ដែងការកើតឡើងរបស់តិជរូប ................ ១៥៦
និព្វានបរមត្ថ ........................................ ១៥៩
វចនត្ថៈរបស់និព្វាន ................................. ១៦០
ឧបមានិព្វាន ......................................... ១៦១
តើអ្វីជានិព្វាន? ...................................... ១៦៦
លក្ខណៈរបស់ព្រះនិព្វាន ......................... ១៦៧
សព្ទសម្ដែងដល់ព្រះនិព្វាន ....................... ១៦៨
រូបវិគ្រោះព្រះនិព្វាន ................................ ១៦៩
លក្ខណាទិតិកៈរបស់ព្រះនិព្វាន................. ១៧១
គុណរបស់ព្រះនិព្វាន ៥.......................... ១៧១
ព្រះនិព្វានមាន ៣.................................. ១៧៣
ឈ្មោះព្រះនិព្វាន ១៤៣ បទ .................... ១៧៣

តើនិព្វាននៅឯណា?................................ ១៩១
និព្វានប្រៀបដោយអាកាស ១០ ប្រការ .......១៩២
អ្នករចនាក្រុបនិងអ្នកពិនិត្យសៀវភៅ ........... ១៩៤
ឯកសារពិគ្រោះ ....................................... ១៩៥

# បុព្វកថា

ខ្ញុំព្រះករុណាអាត្មាភាព ភិក្ខុអគ្គចិត្តោ **យ៉ុន យី** បានរៀបចំសៀវភៅនេះឡើង ដោយចង់ផ្សាភ្ជាប់ជាមួយវីឌីអូអប់រំខ្លី ដែលមានចំណងជើងថា ព្រះអភិធម្មក្នុងជីវិតប្រចាំថ្ងៃ ដោយមានការគាំទ្រពីសំណាក់ញាតិញោម ជាសិក្ខាកាមទាំងឡាយ ដែលជាអ្នកចូលចិត្តសិក្សាព្រះអភិធម្ម តែអ្នកខ្លះមិនមានពេលគ្រប់គ្រាន់ក្នុងការរៀនសូត្រ ហើយមានអ្នកខ្លះទៀតខ្លាចណាស់ឱ្យតែឮ ធម៌អភិធម្មជាធម៌សម្រាប់សូត្រពេលមនុស្សស្លាប់ ឬជាធម៌សម្រាប់អ្នកត្រាស់ដឹងគឺព្រះអរិយៈទើបរៀនកើត។ ហេតុដូច្នេះបានជាខ្ញុំមានគំនិតគិតថា ធ្វើយ៉ាងណាដើម្បីឱ្យមនុស្សយល់ពីមេរៀនអភិធម្មនេះ ដែលជាមេរៀនសំខាន់ក្នុងជីវិតរបស់មនុស្សគ្រប់រូបៗ មិនថា

ចាស់ឬក្មេងទេធម៌របស់ព្រះពុទ្ធ ត្រូវគ្រប់វ័យ គ្រប់សម័យកាល។ ដោយមានការយល់ឃើញបែបនេះ ទើបខ្ញុំបានរៀបចំធ្វើវិឌីអូខ្លីៗឡើង។

**វត្តមណីរតនារាម** ថ្ងៃអាទិត្យ ១ រោច ខែ កត្តិក

ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

**ភិក្ខុអគ្គចិត្តោ យ៉ុន យី**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងអំណរព្រះគុណ និងអរគុណចំពោះ៖

១.ព្រះឧបជ្ឈាយ៍ ពោធិវង្សាវិមល **អ៊ុក ជុំ**

២.លោកម្ចាស់គ្រូព្រះភិក្ខុវជិរប្បញ្ញោ **សាន សុជា**

៣.ព្រមទាំងលោកគ្រូដទៃៗទៀត ដែលបានធ្លាប់ជួយបង្ហាត់បង្រៀនកន្លងមក

៤.សូមអរគុណចំពោះញោម ប្រុស **ចេង យ៉ុន** និងញោមស្រី **ម៉េង ង៉ា** និងលោកយាយ **ចេង ចិន** ជាយាយរបស់ខ្ញុំយ៉ាងក្រៃលែង ដែលបានដឹកនាំខ្ញុំឱ្យបានបួសក្នុងព្រះពុទ្ធសាសនាដ៏ប្រសើរនេះ។

៥.ព្រមទាំងអនុមោទនាចំពោះទឹកចិត្តសទ្ធា ជ្រះថ្លា របស់ញាតិញោមទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា ឧបត្ថម្ភធម្មទានទាំងឡាយនេះ។

ប្រសិនបើមានកំហុសឆ្គង ចំពោះអក្ខរាវិរុទ្ធក្នុង សៀវភៅនេះក្រែងពិនិត្យមិនបានអស់សេចក្តី ឬ យល់សេចក្តីនៃពុទ្ធវចនៈមិនអស់ សូមអភ័យអត់ ទោសអំពីសំណាក់វិញ្ញូជនទាំងឡាយផង។

# ព្រះអភិធម្មក្នុងជីវិតប្រចាំថ្ងៃ

# Abhidhamma in Daily Life.

## បរិច្ឆេទទី ៦ រូបសង្គហវិភាគ

VIDEO 1

### និយមន័យរូប

### Difinition of Matter

វចនត្ថៈ **រុប្បតីតិ** = **រូបំ** ឈ្មោះថា រូប ព្រោះអត្ថថា បែកធ្លាយ រមែងបែកធ្លាយដោយបច្ច័យដែលជាសឹកសត្រូវមានត្រជាក់និងក្តៅជាដើម។

-To be deformed, disturbed or oppressed.

**វិភាវនីដីកា** **សីតុណ្ហាទិវិរោធិប្បច្ចយេហិ រុប្បតីតិ** = **រូបំ** ធម្មជាតិណារមែងបែកធ្លាយដែល

ជាសត្រូវមានត្រជាក់ជាដើម ព្រោះដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា រូប ។

## រូបមាន ៧ ន័យ

**១.រូប** បានដល់ **រូបក្ខន្ធ** ដូចបាលីថា **យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ ។បេ។ អយំ វុច្ចតិ រូបក្ខន្ធោ** រូបណាមួយជាអតីត អនាគត បច្ចុប្បន្ន ។ល។ នេះហៅថា រូបក្ខន្ធ។ (ខន្ធវិភង្គ.៨០ ទំ.២/១)

**២.រូប** បានដល់ **រូបភព** ដូចបាលីថា **រូបូបបត្តិយា មគ្គំ ភាវេតិ** បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព។

**៣.រូប** សំដៅដល់ **និមិត្តក្នុងកសិណ** ដូចបាលីថា **អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ** មិនសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ។

**៤.រូប** សំដៅដល់ **បច្ច័យ ឬហេតុ** ដូចបាលីថា **សរូបា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា** ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមករមែងកើតឡើង ព្រោះបច្ច័យរបស់ខ្លួន។

**៥.រូប** សំដៅដល់ **សរីរៈ** (រាងកាយ) ដូចបាលីថា **អដ្ឋិញ្ច បដិច្ច ន្ហារុញ្ច បដិច្ច មំសញ្ច បដិច្ច ចម្មញ្ច បដិច្ច អាកាសោ បរិវារិតោ**

**រូបក្ខន្ធ សំខ្យំ គច្ឆតិ** អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថា រូបកាយបានដូច្នេះឯង។

**៦.រូប** សំដៅដល់ **វណ្ណៈ** (ពណ៌) ដូចបាលីថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** ប្រែថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុបសាទ និងរូបារម្មណ៍[១]។

---

[១] (អង្គុ.ចក្ក.បត្តកម្មវគ្គ បិ.៤២ទំ.៦៦/១៧៥)

**៧.រូប** សំដៅដល់ **សណ្ឋាន** ទ្រង់ទ្រាយ ដូចបាលីថា **រូបប្បមាណោ រូបសន្នោ** បុគ្គលជ្រះថ្លាក្នុងរូប ឈ្មោះថា រូបប្បមាណ[៧] ។

## សម្ដែងរូបសង្គហៈដោយន័យ ៥

## The Compendium of Matter Is Fivefold

**១.រូបសមុទ្ទេស** សម្ដែងរូបសង្ខេបដើម្បីឱ្យជ្រាបជាលក្ខណៈ (Enumeration)

**២.រូបវិភាគ** សម្ដែងរូបពិស្ដារ ដោយចែកជាគូៗ

---

[៧] មជ្ឈិ.មូល.មូលបរិយាយសូត្រ ២០.២/៤

-Classification

**៣.រូបសមុដ្ឋាន** សម្ដែងហេតុកើតនៃរូប ដោយសមុដ្ឋាន៤ (Origination)

**៤.រូបកលាប** សម្ដែងរូបជាកលាប មានចក្ខុបសាទជាដើម (Groups)

**៥.រូបបវត្តិក្កមន័យ** សម្ដែងលំដាប់ការប្រព្រឹត្តិទៅរបស់រូបដោយការផ្សេងគ្នានៃភព កាល និងសត្វដែលកើតក្នុងភូមិផ្សេងៗ (Modes of occurrence)

## អធិប្បាយរូបន័យទី ១ រូបសមុទ្ទេស

រូប ២៨ ចែកជា២ ប្រភេទធំ

## 28 Material Phenomena Is Twofold

## មហាភូតរូប ៤ ឧបាទាយរូប ២៤

The four great essentials and material phenomena derived from the four great essentials.

## បើចែកតាមប្រភេទតូចៗមាន ១១ពួក

**១.មហាភូតរូប ៤** បានដល់ បឋវី អាបោ តេជោ វាយោ

**២.បសាទរូប ៥** បានដលល់ ចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ កាយបសាទ

**៣.វិសយរូប ៤** បានដល់ វណ្ណៈ សទ្ទៈ គន្ធៈ រសៈ

**៤.ភាវរូប ២** បានដល់ ឥត្ថីភាវៈ បុរិសភាវៈ

**៥.ហទយរូប១** បានដល់ ហទយវត្ថុ (បេះដូង)

**៦.ជីវិតរូប ១** បានដល់ ជីវិតិន្ទ្រិយ

**៧.អាហាររូប ១** បានដល់ កពឡិង្ការាហារ

**៨.បរិច្ឆេទរូប ១** បានដល់ អាកាសធាតុ

**៩.វិញ្ញត្តិរូប ២** បានដល់ កាយវិញ្ញត្តិ វចីវិញ្ញត្តិ

**១០.វិការរូប ៣** បានដល់ លហុតា មុទុតា កម្មញ្ញតា

**១១.លក្ខណរូប ៤** បានដល់ ឧបចយៈ សន្តតិ ជរតា អនិច្ចតា។

## រូប ២៨ ចែកជា ២ ពួកគឺ

សភាវរូប ១ អសភាវរូប ១

សភាវរូបមាន ១៨ គឺ មហាភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អហាររូប ១។

## សភាវរូបមានឈ្មោះហៅ ៥ គឺ

១.**សភាវរូប** រូបដែលមានភាវៈរបស់ខ្លួន

២.**សលក្ខណរូប** រូបដែលមានលក្ខណៈ

៣.**និប្ផន្នរូប** រូបដែលកើតពីសមុដ្ឋាន ៤

៤.**រូបរូប** រូបដែលបែកធ្លាយ

៥.**សម្មសនរូប** រូបដែលគួរពិចារណា

រូប ១០ ទៀតជាអសភាវរូប គឺបរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ មានឈ្មោះហៅបាន ៥ ផ្ទុយពីនេះគឺ អសភាវរូប ១ អលក្ខណរូប១ អនិប្ផន្នរូប ១ អរូបរូប ១ និងអសម្មសនរូប ១ ។

VIDEO 2

# អធិប្បាយ រូប១១ ពួក

## ពួកទី១ មហាភូតរូប ៤

**4 Essential/Great Elements**

ពាក្យថា **មហាភូតរូប** ព្រោះអត្ថថា កើត គឺប្រាកដជាសភាពធំ ក្នុងសន្តានដែលមានចិត្តគ្រប់គ្រង និងមិនមានចិត្តគ្រប់គ្រង ដោយអំណាចនៃធាតុ ព្រមទាំងសម្ភារៈៗ (វិភាវនីដីការ)

## មហាភូតរូបព្រោះហេតុ ៥

១.ព្រោះប្រាកដជារបស់ធំ

២.ព្រោះដូចជាអ្នកលេងកលល្បិច

៣.ព្រោះត្រូវបរិហារ (រក្សា) ច្រើន

៤.ព្រោះវិការៈធំ

៥.ព្រោះជារបស់ធំដែលមានពិត

## ភូតមាន ៧ ន័យ

**១.ភូត** សំដៅដល់ **ភាវៈដែលមាននៅពិត** ដូចបាលី **ថា យោ បន ភិក្ខុ ។បេ។ ភូតស្មឹ បាចិត្តិយំ** ភិក្ខុណាមួយប្រាប់ឧត្តរិមនុស្សធម៌ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ព្រោះភិក្ខុនោះបានពិតមែន។

**២.ភូត** សំដៅដល់ **ខន្ធ ៥** ដូចបាលីថា **ភូតមិទំ ភិក្ខវេ បស្សថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញនូវខន្ធបញ្ចកៈនេះ ដែលកើតឡើងឬទេ។

**៣.ភូត** សំដៅដល់ **រូប** ដូចបាលីថា **ចត្តារោ ខោ ភិក្ខុមហាភូតា ហេតុ** ម្នាលភិក្ខុរូបទាំង ៤ ជាហេតុមហាភូតរូបទាំង ៤ ជាបច្ច័យដែលនាំឱ្យបញ្ញត្តិនូវរូបក្ខន្ធ។

**៤.ភូត** សំដៅដល់ **ព្រះខីណាស្រព** ដូចបាលីថា **យោ ច កាលឃសោ ភូតោ ស ភូតបចនីបចិ** ចំណែកសត្វណាជាអ្នកស៊ីនូវកាល សត្វ

នោះ ឈ្មោះថា ដុតនូវតណ្ហាដែលជាធម្មជាតិ ដុតសត្វ។

**៥.ភូត** សំដៅដល់ **សព្វសត្វ** ដូចបាលីថា **សព្វេ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** ពួកសត្វទាំងអស់មុខជានឹងដាក់ចុះនូវរាងកាយក្នុងលោក។

**៦.ភូត** សំដៅដល់ **ដើមឈើ** ដូចបាលីថា **ភូតគាមបាតព្យតាយ បាចិត្តិយំ** ភិក្ខុធ្វើភូតគាមមានឈើនិងស្មៅជាដើមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។

**៧.ភូត** សំដៅដល់ **អមនុស្ស** ដូចបាលីថា **ភូតេ ភូតតោ សញ្ជានាតិ** សម្គាល់នូវពួកសត្វថា ជាសត្វពិត។

VIDEO 3

**១.បឋវីធាតុ** ( Earth element )

**បឋវីធាតុមានលក្ខណៈ ២**

**១.កក្ខឡ បឋវី** ដីដែលមានភាពរឹង ជាលក្ខណៈ

**២.អថទ្ធ បឋវី** ដីដែលមានភាពមិនរឹង ជាលក្ខណៈ

**វចនត្ថៈ បត្ថីនតេ្ថន = បឋវី** ឈ្មោះថា **បឋវី** ព្រោះអត្ថថា រឹង ។

## បឋវីធាតុមាន ៤ យ៉ាង

**១.បរមត្ថបឋវី ឬលក្ខណបឋវី** = បានដល់ធាតុដីដែលមានភាពរឹង ឬទន់ ជាលក្ខណៈ

**២.សសម្ភារបឋវី ឬសុត្តន្តបឋវី** = បានដល់ធាតុដីមានចំណែកប្រកប មានទាំងក្នុងកាយ និងខាងក្រៅកាយ។

ដែលមានខាងក្នុងកាយសត្វ ជាឧបាទិន្នរូប ហៅថាអជ្ឈត្តិកបឋវី។

ដែលនៅខាងក្រៅកាយសត្វ ជាអនុបាទិន្នរូប ហៅថា ពាហិរបឋវី។

## ខាងក្នុងមាន ២០ គឺ

១.**កេសា** សក់ ២.**លោមា** រោម

៣.**នខា** ក្រចក ៤.**ទន្តា** ធ្មេញ

៥.**តចោ** ស្បែក ៦.**មំសំ** សាច់

៧.**នហារូ** សសៃ ៨.**អដ្ឋិ** ឆ្អឹង

៩.**អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង ១០.**វក្កំ** តម្រងបស្សាវៈ

១១.**ហទយំ** បេះដូង  ១២.**យកនំ** ថ្លើម

១៣.**កិលោមកំ** វាវ  ១៤.**បិហកំ** ក្រពះ

១៥.**បប្ផាសំ** សួត  ១៦.**អន្តំ** ពោះវៀនធំ

១៧.**អន្តគុណំ** ពោះវៀនតូច

១៨.**ឧទរិយំ** អាហារថ្មី

១៩.**ករីសំ** អាហារចាស់

២០.**មត្ថលុង្គំ** ខួរក្នុងក្បាល។

**ពាហិរបឋវី** មានដូចជា **អយោ** ដែក **លោហំ** លោហៈ **តិបុ** សំណប៉ាហាំង **សីសំ** សំណភក់ **សជ្ឈុ** ប្រាក់ **មុត្តា** កែវមុក្តា **មណិ** កែវមណីជាដើម។

**៣.កសិណបឋវីឬអារម្មណបឋវី** = បានដល់បឋវីកសិណ ឬ ដីដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន។

**៤.សម្មុតិបឋវី ឬបកតិបឋវី** បានដល់ធាតុដីដែលសន្មត ហៅថា ដី ដុំដី ទីដី ផ្ទៃដី ផែនដី។

VIDEO 4

## ២.អាបោធាតុ (Water Element)

## អាបោធាតុ ធាតុទឹកមានលក្ខណៈ ២

១.**បគ្ឃរណរសអាបោ** ធាតុទឹកដែលមានលក្ខណៈហូរជ្រាប

២.**អាពន្ធនអាបោ** ធាតុទឹកដែលមានលក្ខណៈជាប់ស្អិត។

វត្ថុណាមានអាបោធាតុច្រើន វត្ថុនោះ ក៏រាវនិងហូរទៅ បើមានអាបោធាតុតិច ក៏ធ្វើឱ្យវត្ថុនោះជាប់ស្អិតគ្នាជាដុំ គឺជាប់ស្អិត បរមាណូបឋវីធាតុ ឱ្យជាដុំជាប់

គ្នា ជារូបរាងសណ្ឋានផ្សេងៗ ដូចជាផែនដី ភ្នំ ដើមត្នោត ទំពាំង ភ្លុកដំរី ជាដើម បើវត្ថុណាមានអាបោធាតុច្រើនជាងបឋវីធាតុ ក៏ធ្វើឱ្យបឋវីធាតុមានភាពរឹងតិច និងធ្វើឱ្យបឋវីធាតុ ដែលកើតរួមគ្នានោះ ហូរទៅ ដូចទឹកក្នុងទន្លេ ស្ទឹងជាដើម។

វចនត្ថៈ **អាបេតិ សហជាតរូបានិ បត្ថរតិ អប្បាយតិ វា ព្រូហេតិ វឌ្ឍេតីតិ = អាបោ** ដែលឈ្មោះថា **អាបោ** ដោយអត្ថថា ជ្រួតជ្រាប គឺជ្រើមទៅកាន់រូប ដែលកើតរួមគ្នា។ ម្យ៉ាងទៀតឈ្មោះថា **អាបោ** ដោយអត្ថថា ធ្វើឱ្យសហជាតរូបជិតស្និត កពូន ឬចម្រើន ដុះដាល ធំធាត់។

## អាបោធាតុមាន ៤ យ៉ាង

**១.បរមត្ថអាបោ ឬលក្ខណអាបោ** បានដល់ធាតុទឹកដែលជាបរមត្ថ

**២.សសម្ភារអាបោឬសុតន្តអាបោ** បានដល់ធាតុទឹកព្រមទាំងគ្រឿងប្រកប។

អាបោធាតុមានខាងក្នុងរាងកាយហៅថា **អជ្ឈត្តិកអាបោ**។

អាបោធាតុខាងក្រៅរាងកាយ ហៅថា **ពាហិរអាបោ**។

# ខាងក្នុងរាងកាយមាន ១២ គឺ

១.**បិត្តំ** ទឹកប្រមាត់ ២.**សេម្ហំ** ស្លេស្ម

៣.**បុព្វោ** ទឹកខ្ទុះ ៤.**លោហិតំ** ឈាម

៥.**សេទោ** ញើស ៦.**មេទោ** ខ្លាញ់ខាប់

៧.**អស្សុ** ទឹកភ្នែក ៨.**វសា** ខ្លាញ់រាវ

៩.**ខេឡោ** ទឹកមាត់

១០.**សិង្ឃាណិកា** ទឹកសម្បោរ

១១.**លសិកា** ទឹករំអិល

១២.**មុត្តំ** ទឹកមូត្រ។

## ធាតុទឹកដែលនៅខាងក្រៅមានដូចជា

**មូលរសោ** រសគល់ **ខន្ធរសោ** រសដើម **តចរសោ** រសសំបក **បត្តរសោ** រសស្លឹក **បុប្ផរសោ** រសផ្កា **ផលរសោ** រសផ្លែ ជាដើម។

**៣.កសិណអាបោ ឬអារម្មណអាបោ** បាន ដល់ អាបោកសិណ ឬទឹកដែលជាអារម្មណ៍របស់ សមថកម្មដ្ឋាន មានទឹកក្នុងបាត្រក្នុងអាង ក្នុងផ្តិល ជាដើម។

**៤.សម្មតិអាបោ ឬបកតិអាបោ** បានដល់ ធាតុទឹកដែលសន្មតគ្នាថា ទឹកផឹក ទឹកងូតជាដើម។

VIDEO 5

## ៣.តេជោធាតុ (Fire element)

## ធាតុភ្លើងមាន ២ លក្ខណៈគឺ

១.**ឧណ្ហតេជោ** ភ្លើងគឺចំហាយក្តៅ

២.**សីតតេជោ** ភ្លើងគឺចំហាយដែលត្រជាក់។

**វចនត្ថៈ តេជេតិ បរិបាចេតីតិ** = **តេជោ** ធាតុដែលឈ្មោះថា តេជោ ព្រោះអត្ថថា ធ្វើឱ្យក្តៅ ឱ្យឆ្អិន

គឺធ្វើភូតរូប៣ ដែលនៅសល់ឱ្យក្តៅ ឬត្រជាក់ ដោយភាវៈរបស់ខ្លួន។

## តេជោធាតុមាន ៤ យ៉ាង

**១.បរមត្ថតេជោ ឬលក្ខណតេជោ** ធាតុភ្លើងដែលជាបរមត្ថ

**២.សសម្ភារតេជោ ឬសុត្តន្តតេជោ** ធាតុភ្លើងព្រមទាំងចំណែកប្រកប។

## អជ្ឈត្តិកមាន ៤ យ៉ាង

**១.ឧស្មាតេជោ** ភ្លើងដែលធ្វើឱ្យរាងកាយក្តៅ

២.**បាចកតេជោ** ភ្លើងរំលាយអាហារ

៣.**ជីរណតេជោ** ភ្លើងដែលធ្វើឱ្យទ្រុឌទ្រោម មានធ្មេញបាក់ជាដើម

៤.**សន្តាបនតេជោ** ភ្លើងដែលធ្វើឱ្យក្តៅ រហូតដល់មានជំងឺ។

**ពាហិរតេជោ** មានដូចជា ភ្លើងឧស ភ្លើងរំកាច់ ភ្លើងស្មៅ ភ្លើងអាចម៍គោ ភ្លើងអង្គាមឬចំបើង ភ្លើងសំរាមជាដើម។

**៣.កសិណតេជោ ឬអារម្មណតេជោ** បានដល់ តេជោកសិណ ឬភ្លើងដែលជាអារម្មណ៍របស់សមថៈ។

**៤.សម្មុតិតេជោ ឬបកតិតេជោ** បានដល់ភ្លើងដែលសន្មតដូចភ្លើងអគ្គិសនី ភ្លើងចង្កៀងជាដើម។

VIDEO 6

## ៤.វាយោធាតុ (Air element)

## ធាតុខ្យល់មាន ២ លក្ខណៈគឺ

**១.ឧត្ថម្ភនវាយោ** ខ្យល់ដែលធ្វើឱ្យតឹង

**២.សម្ភីរណវាយោ ឬសមីរណវាយោ** ខ្យល់ដែលធ្វើឱ្យកម្រើក។

**វចនត្ថៈ វាយតិ សហជាតធម្មេ អបតមានេ ករោ ខលីតិ = វាយោ** ធាតុណា រមែងបក់ផាត់ រមែងនាំទៅនូវរូប ដែលកើតព្រមជាមួយខ្លួនធ្វើមិនឱ្យកម្រើកញ័រ ព្រោះហេតុនោះ ធាតុនោះឈ្មោះថា **វាយោ** បានដល់ ដែលធ្វើឱ្យតឹង។

## វាយោធាតុមាន ៤

**១.បរមត្ថវាយោ ឬលក្ខណវាយោ** បានដល់ធាតុខ្យល់ដែលមានសភាវៈជាបរមត្ថ

២.**សសម្ភារវាយោ ឬសុត្តន្តវាយោ** បាន ដល់ ធាតុខ្យល់ព្រមទាំងចំណែកប្រកប មានទាំងខាងក្នុង និងខាងក្រៅ។

## អជ្ឈត្តិកវាយោ មាន ៦ យ៉ាង

១.ខ្យល់បក់ឡើងលើ

២.ខ្យល់បក់ពីលើចុះក្រោម

៣.ខ្យល់ដេកក្នុងផ្ទៃ (ខ្យល់ខាងក្រៅពោះវៀន)

៤.ខ្យល់ក្នុងក្រពះ (ខ្យល់ក្នុងពោះវៀន)

៥.ខ្យល់ផ្សព្វផ្សាយសព្វអវយវៈតូចធំ

៦.ខ្យល់ដកដង្ហើមចូល ចេញ។

**ពាហិរវាយោ** មានដូចជា ខ្យល់បក់មកពីទិសខាងកើត ខ្យល់បក់មកពីទិសខាងលិច ខ្យល់បក់មកពីទិសខាងជើង ខ្យល់បក់មកពីទិសខាងត្បូង ខ្យល់មានធូលី ខ្យល់មិនមានធូលីជាដើម។

៣.**កសិណវាយោ ឬអារម្មណវាយោ** បានដល់ វាយោកសិណ ឬខ្យល់ដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន។

៤.**សម្មុតិវាយោ ឬ បកតិវាយោ** បានដល់ខ្យល់ធម្មតា ដែលបក់ផាត់ទៅមក។

VIDEO 7

# ពួកទី២ បសាទរូប ៥

## Sensitive Phenomena

**បសីទន្តីតិ** = **បសាទា** ឈ្មោះថា ប្រសាទ ព្រោះអត្ថថា ផូរផង់ ស្រស់ថ្លា។ (បរមត្ថទីបនី)

បសាទរូបមាន ៥ គឺ ចក្ខុបសាទ សោតបសាទ ឃានបសាទ ជិវ្ហាបសាទ កាយបសាទ ។

**ចក្ខុបសាទ** មានភាពថ្លានៃភូតរូបគួរប៉ះខ្ទប់ជាមួយពណ៌ ជាលក្ខណៈ

## ១.ចក្ខុបសាទរូប (Eye-sensitivity)

មានការថ្លាដូចកញ្ចក់ឆ្លុះស្រមោល ដែលអាស្រ័យមហាភូតរូប ៤ នៅក្នុងសសម្ភារៈចក្ខុ។ ចក្ខុបសាទនេះផ្សាយពេញក្រពេញភ្នែករហូតដល់ ៧ ជាន់ ដូចប្រេងដែលស្រោចចុះលើសំឡី៧ ជាន់ក្នុងមណ្ឌលភ្នែកដែលឃើញរូប ដូចជាផ្ទៃកើតឡើងនៃសរីរៈសណ្ឋានរបស់បុគ្គលដែលនៅចំពោះមុខ ក្នុងកណ្ដាលនៃរង្វង់ភ្នែកខ្មៅដែលព័ទ្ធជុំវិញ។

**ព្រះធម្មសេនាបតីពោលថា៖**

សត្វរមែងឃើញរូបទាំងឡាយ ដោយចក្ខុប្រសាទរូបណា ចក្ខុប្រសាទរូបនេះ តូចល្អិត មានប្រមាណប៉ុនក្បាលចៃ។

**វចនត្ថៈ ចក្ខុវិញ្ញាណដ្ឋិតំ ហុត្វា សមវិសមំ ចក្ខតិ អាចិក្ខន្តំ វិយ ហោតីតិ** = **ចក្ខុ** រូបណា ជាទីតាំងនៃចក្ខុវិញ្ញាណ ប្រាប់គឺរមែងដូចជាប្រាប់ថា ពណ៌ល្អ និងមិនល្អ ព្រោះហេតុនោះ រូបដែលដូចជាប្រាប់នោះ ទើបឈ្មោះថា **ចក្ខុ** បានដល់ចក្ខុប្រសាទរូប។

# ចក្ខុមាន ២ ប្រភេទ

១.**មំសចក្ខុ** បានដល់ ភ្នែកសាច់ មាន២ យ៉ាងគឺ

ក.**បសាទចក្ខុ**

ខ.**សសម្ភារចក្ខុ** ដុំសាច់ដែលនៅក្នុងគ្រប់ភ្នែក។

## មំសចក្ខុសង្ខេបមាន ១៤

មហាភូតរូប ៤ វណ្ណៈ គន្ធៈ រសៈ ឱជា សម្ភវៈ (ការកើតឡើង) សណ្ឋាន (ការតាំងនៅ) ជីវិត ភាវៈ កាយបសាទ និងចក្ខុបសាទ។

ពិស្តារមាន ៤៤ គឺ មហាភូតរូប៤ វណ្ណៈ គន្ធៈ រសៈ ឱជា សណ្ឋាន សម្ភវៈ រូប១០នេះ អាស្រ័យមហាភូតរូប ៤ ទើបជា ៤០ និងសសម្ភារៈមានកម្មជាសមុដ្ឋានតែម្យ៉ាង៤ ទៀត គឺជីវិត ភាវៈ កាយបសាទ និងចក្ខុបសាទ។

## ២.បញ្ញាចក្ខុមាន ៥

១.**ពុទ្ធចក្ខុ** ព្រះនេត្ររបស់ព្រះពុទ្ធ ដែលជ្រាបនិស្ស័យបារមីរបស់សត្វ មានអាសយានុសយញ្ញាណជាដើម បានដល់ មហាកិរិយាញាណសម្បយុត្តចិត្ត៤ ។

២.**សមន្តចក្ខុ** ព្រះនេត្រដែលដឹងធម៌ដោយជុំវិញ បានដល់ បញ្ញាដែលដឹងធម៌ទាំងពួង ទាំងបញ្ញត្តិនិងបរមត្ថ (មហាកិរិយាញាណសម្បយុត្តចិត្ត៤)។

៣.**ញាណចក្ខុ** ព្រះនេត្រដែលជាប្រាជ្ញាត្រាស់ដឹងធម៌ បានដល់ បញ្ញាក្នុងអរហត្តមគ្គចិត្ត[១]។

៤.**ទិព្វចក្ខុ** ភ្នែកទិព្វដែលអាចមើលឃើញឆ្ងាយ (អភិញ្ញាចិត្ត ២) ។

---

[១] (វិន.មហាខន្ធក.ភាគ៦ ទំ.១៥.៣១)

៥.**ធម្មចក្ខុ** ភ្នែកឃើញធម៌ដែលជាត្រៃលក្ខណ៍ បានដល់ បញ្ញាក្នុងមគ្គ ៣ ខាងក្រោម ដែលព្រះអង្គត្រាស់ថា ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ឧបលិគហបតី ក្នុងកន្លែងអង្គុយនោះឯង [១]។

## វេវចនរបស់ចក្ខុ ១៤ បទ

១.**ចក្ខុ** ជាអ្នកត្រួតត្រាក្នុងការឃើញ

២.**ចក្ខាយតនៈ** ជាទីប្រជុំចុះកំណើតរបស់ខ្លួន

---

[១] ឧបាលិវាទសូត្រ ២៣.៧៤/១១៤

៣.**ចក្ខុធាតុ** ជាសភាវៈសូន្យ ទាំងមិនមែនជាសត្វ

៤.**ចក្ខុន្ទ្រិយ** មាននាទីខាងការឃើញ

៥.**លោក** ជារបស់សម្រាប់វិនាស

៦.**ទ្វារ** ជារបស់សម្រាប់បើកបិទ

៧.**សមុទ្រ** បំពេញបានដោយកម្រ

៨.**បណ្ឌារៈ** ជារបស់ថ្លាបរិសុទ្ធ

៩.**ខេត្ត** ជាកន្លែងកើតផស្សៈជាដើម

១០.**វត្ថុ** ជាទីតម្កល់ផស្សៈជាដើម

១១.**នេត្រ** បង្ហាញទីស្មើនិងមិនស្មើ

១២.**នយនៈ** ដូចគ្នានឹងនេត្រា

១៣.**ទ្រើយអាយ** រាប់បញ្ចូលខាងក្នុងកាយខ្លួន

១៤.**ស្រុកធំនេះ** ព្រោះជារបស់សាធារណៈដល់ជនច្រើន ទាំងគ្មានម្ចាស់[៥]។

VIDEO 8

## ២.សោតបសាទរូប (Ear-sensitivity)

[៥] (បិ.៧៩ ទំ.១៦.២១)

វចនត្ថៈ **សោតវិញ្ញាណដ្ឋិតំ ហុត្វា សទ្ទំ សុណាតីតិ = សោតំ** រូបណា ជាទីតាំងរបស់សោតវិញ្ញាណ រមែងស្តាប់សំឡេង ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា សោត បានដល់ សោតប្រសាទរូប។

សោតប្រសាទនេះ មានសណ្ឋានដូចវង់ចិញ្ចៀន មានរោមក្រហមដុះឡើង។

**សោតបសាទ** មានភាពថ្លានៃភូតរូបគួរដល់ការប៉ះខ្ទប់ជាមួយសំឡេង ជាលក្ខណៈ។

# សោតមាន ៣ យ៉ាង

១.**ទិព្វសោត** បានដល់ សោតញាណ ឬទិព្វសោត អភិញ្ញា ២

២.**តណ្ហាសោត** បានដល់ សោត គឺតណ្ហា

៣.**មំសសោត** បានដល់ ប្រសាទសោត និង សសម្ភារសោត។

# សោត ៧ ន័យ

**១.សោត** គឺរូប ហៅថា សោតាយតន សោតធាតុ សោតិន្ទ្រិយក៏បាន។

២.**សោត** គឺ សោតវិញ្ញាណ ដូចឮសំឡេងដោយត្រចៀកជាដើម។

៣.**សោត** គឺទិព្វសោត ដូចឮសំឡេងដោយទិព្វសោត។

៤.**សោត** គឺ កិលេស សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមានក្នុងលោក។

៥.**សោត** គឺ ក្រសែទឹក ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើធំ កំពុងអណ្តែតតាមក្រសែទឹកក្នុងឆ្នេរទន្លេគង្គា។

៦.**សោត** បានដល់ អរិយមគ្គ ម្នាលអាវុសោ សោតៈ នេះ ជាឈ្មោះនៃអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ។

៧.**សោត** គឺការបន្តនៃចិត្ត ទាំងដឹងច្បាស់នូវការបន្តនៃចិត្ត (វិញ្ញាណសោត) របស់បុរស។

VIDEO 9

**៣.ឃានបសាទ (Nose-sensitivity)**

**វចនត្ថៈ ឃាយតីតិ** = **ឃានំ** ឈ្មោះថា ឃាន ព្រោះអត្ថថា ស្រូបក្លិន បានដល់ ឃានប្រសាទរូប។

**ឃានបសាទ** មានភាពថ្លានៃភូតរូបដែលគួរប៉ះខ្ទប់ជាមួយក្លិន ជាលក្ខណៈ។

## មំសឃាន មាន ២ គឺ

ប្រសាទឃាន ១ សសម្ភារឃាន១ ។

VIDEO 10

## ៤.ជិវ្ហាបសាទរូប (Tongue-Sensitivity)

**វចនត្ថៈ ជីវិតំ អវ្ហាយតីតិ = ជិវ្ហា** ឈ្មោះថា ជិវ្ហា ព្រោះអត្ថថា នាំមកនូវជីវិត (គឺរូបហៅរករស) បានដល់ ជិវ្ហាប្រសាទរូប។

មានសណ្ឋានដូចត្របកផ្កាឧប្បល។

**ជិវ្ហាបសាទ** មានភាពថ្លានៃភូតរូបដែលគួរប៉ះខ្ទប់ជាមួយរស ជាលក្ខណៈ។

**មំសជិវ្ហា ២** គឺ ប្រសាទជិវ្ហា១ និងសសម្ភារជិវ្ហា១។

VIDEO 11

## ៥.កាយបសាទរូប (Body-sensitivity)

វចនត្ថៈ **កុច្ឆិតានំ កេសាទីនំ បាបធម្មានញ្ច អាយោតិ = កាយោ** ធម៌ណា ជាទីប្រជុំនៃកោដ្ឋាសមានសក់ជាដើម និងជាទីប្រជុំនៃបាបធម៌ ដែលបណ្ឌិតស្អប់ខ្ពើម ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **កាយ** បានដល់ រូបកាយ និងនាមកាយ។

ក្នុងទីនេះ សំដៅដល់ កាយប្រសាទរូបដែលមានសភាពថ្លាផ្សាយទូទៅទាំងសរីរៈ ដូចជាជ័រសរសៃនៃកប្បាស។

**កាយបសាទ** មានភាពថ្លានៃភូតរូបដែលគួរប៉ះខ្ទប់ជាមួយផោដ្ឋព្វារម្មណ៍ ជាលក្ខណៈ។

## កាយ ៤ យ៉ាង

១.**ប្រសាទកាយ** គឺកាយប្រសាទរូប

២.**រូបកាយ** គឺរូបធម៌ទាំងអស់

៣.**នាមកាយ** គឺចិត្តនិងចេតសិក

៤.**បញ្ញត្តិកាយ** គឺសមូហបញ្ញត្តិ

## កាយ ៤ យ៉ាងទៀត

១.**ចោបនកាយ** កាយឃ្លាតកម្រើកញ័រ ឬការឱ្យកម្រើកញ័រ

២.**ករជកាយ** កាយកើតអំពីធូលីក្នុងទឹក

៣.**សមូហកាយ** កាយដែលប្រជុំគ្នា

៤.**ប្រសាទកាយ** កាយប្រសាទរូប។

# VIDEO 12

## ពួកទី៣ វិសយរូប ៧

**Objective Phenomena**

**វិសយរូប ឬគោចររូប** រូបដែលជាអារម្មណ៍របស់ចិត្ត និងចេតសិក ដែលកើតតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។

**វិសយរូប ៤** គឺ វណ្ណៈ សទ្ទៈ គន្ធៈ រសៈ

ផោដ្ឋព្វារម្មណ៍ ៣ គឺ បឋវី១ តេជោ១ វាយោ១ រួមជា វិសយរូប ៧។

**វចនត្ថៈ គោចររូបនាម បញ្ចវិញ្ញាណវិសយភាវតោ** រូប (ពណ៌) ជាដើម ឈ្មោះថាគោចររូប ព្រោះជាអារម្មណ៍របស់បញ្ចវិញ្ញាណ។

**គោចោ ឥន្ទ្រិយានិ ចរន្តិ ឯត្ថាតិ** = **គោចរំ** ដែលឈ្មោះថា **គោចររូប** ព្រោះអត្ថថា ជាទីត្រាច់ទៅនៃគោចរ គឺឥន្ទ្រិយទាំងឡាយ។

## **១.រូបារម្មណ៍** (ពណ៌) (Visible form)

**រូប** ព្រោះអត្ថថា សម្ដែង គឺប្រកាសភាពជាអារម្មណ៍ទៅកាន់ហទយ គឺរូបដែលធ្វើ ឱ្យដឹងសេចក្ដីផ្សេងៗ។

**រូបារម្មណ៍** មានការប៉ះខ្ទប់នឹងចក្ខុបសាទ ជាលក្ខណៈ។

## ២.សទ្ទារម្មណ៍ (សំឡេង) (Sound)

សំឡេង ដែលគេថ្លែងចេញ គឺរមែងឱ្យលាន់ឮ សំឡេងកើតពីចិត្ត។ រូបណារមែងថ្លែងចេញ គឺរមែងដល់ភាវ ឱ្យសោតវិញ្ញាណដឹង បានដល់ សំឡេងដែលកើតពីចិត្ត ឬឧតុជាសទ្ទារម្មណ៍។

**សទ្ទារម្មណ៍** មានការប៉ះខ្ទប់នឹងសោតបសាទ ជាលក្ខណៈ។

## ៣.គន្ធារម្មណ៍ ( ក្លិន) (Smell)

គន្ធៈ ព្រោះអត្ថថា បញ្ចេញក្លិន គឺរមែងប្រាប់នូវវត្ថុរបស់ខ្លួន។

**គន្ធារម្មណ៍** មានការប៉ះខ្ទប់នឹងឃានបសាទ ជាលក្ខណៈ។

## គន្ធៈ៤ យ៉ាង

១.**សីលគន្ធៈ** សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ

២.**សមាធិគន្ធៈ** សម្មាវាយាម សម្មាសតិ សម្មាសមាធិ

៣.**បញ្ញាគន្ធៈ** សម្មាទិដ្ឋិ សម្មាសង្កប្បៈ

៤.**អាយតនគន្ធៈ** គន្ធារម្មណ៍។

## ៤.រសារម្មណ៍ (រស) (Taste)

**រស** ព្រោះអត្ថថា ជិវ្ហាវិញ្ញាណ រមែងត្រេកអរ គឺពេញចិត្ត។

**រសារម្មណ៍** មានការប៉ះខ្ទប់នឹងជិវ្ហាប្រសាទ ជាលក្ខណៈ។

## រស មាន ៤ យ៉ាង

១.**ធម្មរស** បានដល់ មគ្គចិត្តុប្បាទ ៤

២.**អត្ថរស** បានដល់ ផលចិត្តុប្បាទ ៤

៣.**វិមុត្តិរស** បានដល់ ព្រះនិញ្វាន

៤.**អាយតនរស** បានដល់ រសារម្មណ៍ ដូចរសប្រៃ រសផ្អែម ជាដើម។ (ម្នាលបបហារាទ ធម្មវិន័យនេះ មានរសតែមួយ គឺវិមុត្តិរស)។

**៥.ផោដ្ឋព្វារម្មណ៍ (សម្ផស្ស) (Tangibility)**

**ផោដ្ឋព្វៈ** ព្រោះអត្ថថា ដែលភូតរូប ៣ (វៀរអាបោធាតុ) គប្បីប៉ះខ្ទប់។

រួម មហាភូតរូប៣ ជាវិសយរូបមាន ៧។

**ផោដ្ឋព្វារម្មណ៍** មានភាពថ្លានៃភូតរូបគួរដល់ការប៉ះខ្ទប់នឹងផោដ្ឋព្វារម្មណ៍ ជាលក្ខណៈ។

VIDEO 13

## ពួកទី៤ ភាវរូប ២

## Sexual Phenomena

### ១.ឥត្ថីភាវរូប (Femininity)

**វចនត្ថៈ ឥត្ថិស្ស ភាវោ = ឧទ្ធច្ចំ** ភាវៈនៃស្រី ឈ្មោះថា **ភាពជាស្រី** ។

**ឥត្ថីភាវរូប** មានភាពជាស្រី ជាលក្ខណៈ។

# គ្រឿងសំគាល់របស់មនុស្សស្រី៤ ប្រភេទ

១.**លិង្គ** រូបរាងសណ្ឋានមានដៃ ជើង ភ្នែក ភេទជាដើម។

២.**និមិត្ត** ជាគ្រឿងចំណាំ ដូចជាសំឡេង ការញញឹមជាដើម។

៣.**កុត្ត** និស្ស័យគឺការប្រព្រឹត្តិផ្សេងៗ ដូចជាការលេង ការលក់ដូរ ការវាយតប់ជាដើម។

៤.**អាកប្ប** អាការកិរិយា ដូចជាដើរ ឈរ អង្គុយដេក បរិភោគ និយាយជាដើម។ (វិភាវនីដីការ)

## ១.បុរិសភាវរូប (Masculinity)

**វចនត្ថៈ បុរស្ស ភាវោ = ឧទ្ធច្ចំ** ភាវៈនៃបុរស ឈ្មោះថា **ភាពជាប្រុស** ។

**បុរិសភាវរូប** មានភាពជាប្រុស ជាលក្ខណៈ។

## គ្រឿងសម្គាល់របស់មនុស្សប្រុស៤ ប្រភេទ

១.**លិង្គ** មានទ្រង់ទ្រាយ មានដៃជាដើម។

២.**និមិត្ត** ជាគ្រឿងចំណាំ មានពុកមាត់ពុកចង្ការ។

៣.**កុត្ត** និស្ស័យគឺការប្រព្រឹត្តិផ្សេងៗ។

៤.**អាកប្ប** អាការកិរិយា ដូចជាដើរជាដើម។

VIDEO 14

## ពួកទី៥ ហទយរូប

## Heart phenomenon

## ហទយរូបមាន ២ គឺ

**១.មំសហទយរូប** បានដល់ សាច់ដុំបេះដូង ដូចផ្កាឈូកក្រពុំសំយុងចុះ ជាទីអាស្រ័យរបស់មនោធាតុនិងមនោវិញ្ញាណធាតុ ។

**២.វត្ថុហទយរូប** គឺជាសុខុមរូបដែលកើតពីកម្មជាសមុដ្ឋាន មានទំហំប៉ុនគ្រាប់បុសនាគមានលោហិតប្រមាណមួយទូកដៃ។

**ហទយវត្ថុ** មានភាពជាទីអាស្រ័យរបស់មនោធាតុ និងមនោវិញ្ញាណធាតុ ជាលក្ខណៈ។

## ពណ៌ទឹកលោហិតតាមចរិត ៦

១.**រាគចរិត** មានពណ៌ក្រហម

២.**ទោសចរិត** មានពណ៌ខ្មៅ

៣.**មោហចរិត** មានពណ៌ដូចទឹកលាងសាច់

៤.**វិតក្កចរិត** មានពណ៌ដូចស្រោមសណ្ដែកខ្មៅ

៥.**សទ្ធាចរិត** មានពណ៌លឿងដូចផ្កាកណ្ណិការ

៦.**ពុទ្ធិចរិត** មានពណ៌ភ្លឺថ្លាបរិសុទ្ធ ដូចកែវមណីផ្ទៃហើយ។

**វចនត្ថៈ ហទន្តិ សត្តា តំ តំ អត្ថំ ឯវា ឞូរេន្តិ ឯតេនាតិ = ហទយំ** សត្វទាំងឡាយ រមែងគិត រមែងញ៉ាំងប្រយោជន៍ និងវត្ថុដែលមិនមែនប្រយោជន៍នោះៗ ឱ្យពេញបានដោយរូបនោះ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា ហទយៈ។

VIDEO 15

# ពួកទី ៦ ជីវិតរូប

## Life phenomenon

## ជីវន្តិ សហជាតធម្មា ឯតេនាតិ = ជីវិតំ

សហជាតធម៌ទាំងឡាយ រមែងរស់នៅដោយរូបនេះ ព្រោះហេតុនោះ រូបនេះ ទើបឈ្មោះថា ជីវិត។

ជីវិតរូប គឺជាកម្លាំងរបស់កម្មជរូបដែលផ្សាយទូទៅសព៌ាង្គកាយ។ ការរស់នៅបានក៏ព្រោះដោយសារមានជីវិតរូបជាអ្នករក្សា។

**ជីវិតរូប** មានការតាមរក្សារូបដែលកើតព្រមគ្នាជាលក្ខណៈ។

VIDEO 6

## ពួកទី ៧ អាហាររូប

**Nutritional Phenomenon**

វចនត្ថៈ **កពឡិំ កត្វា អជ្ឈោហរិយតីតិ** = **កពឡីការោ អាហារោ** ឈ្មោះថា **កវឡិង្ការាហារ** ព្រោះអត្ថថា ដែលបុគ្គលធ្វើឱ្យជាពំនូត ហើយបរិភោគ។ អាហារក្នុងទីនេះ សំដៅដល់ ឱជារស ដែលញ៉ាំងរាងកាយនេះឱ្យរស់នៅបន្តបាន។

**អាហាររូប** មានការធ្វើឱ្យរូបចម្រើន ជាលក្ខណៈ។

VIDEO 16

## ពួកទី៨ បរិច្ឆេទរូប (រូបកំហិត)

**Limiting Phenomenon**

**វចនត្ថៈ ន កស្សតីតិ = អាកាសោ អាកាស យេវ អាកាសោ** ប្រទេសឈ្មោះថា **អាកាស** ព្រោះអត្ថថា ដែលបុគ្គលធ្វើឱ្យជាស្នាមមិនបាន អាកាសនុ៎ះឯងឈ្មោះថា អាកាស។

**បរិច្ឆេទរូប** គឺជាអាកាសរវាងអាតូម ឬខាងក្នុងអាតូម ដែលកំណត់កំហិត ឬបំបែកសំណុំរូប(រូបកលាប) ។

បរិច្ឆេទរូបម្យ៉ាងទៀតហៅថា អាកាសធាតុ គឺលម្ហក្នុងខ្លួនឯងដែលគ្មានអ្វីសោះ។

**បរិច្ឆេទរូប** មានការកំណត់នូវរូប ជាលក្ខណៈ។

## អាកាស ៤ យ៉ាង

១.**អជដាកាស** អាកាសល្ហល្ហេវទទេ

២.**បរិច្ឆិន្នាកាស** អាកាសចន្លោះទទេ ដូចចន្លោះបង្អួច ប្រទ្បោះមាត់ជាដើម

៣.**កសិណុគ្ឃាដិមាកាស** អាកាសដែលបើកចេញពីកសិណ ៩ (វៀរអាកាសកសិណ)

៤.**បរិច្ឆេទាកាស** អាកាសចន្លោះប្រឡោះទទេ ដែលឃាំងរវាងរូប និងរូប គឺរវាងកលាប និង កលាប។

VIDEO 17

## ពួកទី៩ វិញ្ញត្តិរូប ២ (រូបទាក់ទង)

## Communicating Phenomena

**វិញ្ញត្តិរូប** ជាអាកប្បកិរិយារបស់រាងកាយនិងមាត់ ដែលបុគ្គលប្រើសម្រាប់ទាក់ទង គំនិតរបស់ខ្លួនឯង ទៅជាមួយនឹងអ្នកឯទៀត និងតាមមធ្យោបាយណា មួយ។

**១.កាយវិញ្ញត្តិរូប** ការធ្វើដោយដៃ ក្បាល ភ្នែក ជើងជាដើមឱ្យអ្នកដទៃយល់នូវបំណងរបស់ខ្លួន។

-Bodily intimation

**២.វចីវិញ្ញត្តិរូប** ចលនារបស់មាត់បង្កើតសម្ដី ដើម្បីឱ្យអ្នកដទៃយល់នូវបំណងរបស់ខ្លួន។

-Vocal intimation

បុថុជ្ជន ព្រះសេក្ខបុគ្គល និងអសេក្ខបុគ្គល រមែងឱ្យវិញ្ញត្តិទាំង២ កើតដោយចិត្ត ៣២ គឺ មហាកុសលចិត្ត ៨ អភិញ្ញាចិត្ត២ អកុសលចិត្ត ១២ មហាកិរិយាចិត្ត ៨ បរិត្តកិរិយាចិត្ត ២។

VIDEO18

# ពួកទី១០ វិការរូប ៣

## Mutable Phenomena

**វចនត្ថៈ វិសេសោ អាការោ** = **វិការោ** អាការៈវិសេសរបស់និប្ផន្នរូប ឈ្មោះថា វិការៈ។

ព្រះមហាថេរឡេឌី សយាដ័រ ពន្យល់ថា វិការរូប ជាសភាវៈច្បាស់ប្លែក ឯព្រះនារទៈយល់ថា ជាសភាពផ្លាស់ប្តូរបានរបស់រូប។

១.**រូបស្ស លហុតា** = ភាពស្រាលនៃរូបសង្កត់សង្កិន ភាពធូន់ក្នុងរាងកាយ។ (Lightness)

**រូបលហុតា** មានការមិនយឺតយូរ ជាលក្ខណៈ។

២.**រូបស្ស មុទុតា** = ភាពទន់នៃរូប កម្ចាត់នូវភាពរឹងក្នុងរាងកាយនិងប្រៀបដូចស្បែកដែលគេសម្លាប់ល្អហើយ។ (Malleabibilty)

**រូបមុទុតា** មានការមិនរឹង ជាលក្ខណៈ។

៣.**រូបស្ស កម្មញ្ញតា** = ភាពស៊ាំនៃរូប បដិបក្សនឹងភាពរឹងនៃកាយ និងប្រៀបធៀបដូចមាសដែលគេរំលាយបានល្អហើយ។ (Wieldiness)

**រូបកម្មញ្ញតា** មានការគួរដល់ការងារ ជាលក្ខណៈ។

VIDEO 19

# ពួកទី១១ លក្ខណរូប ៤

## Characteristics of Matter

**វចនត្ថៈ លក្ខីយន្តិ វិនិច្ឆយន្តិ ធម្មា ឥមេ សង្ខតាតិ ឯតេនាតិ = លក្ខណំ** ធម៌ទាំងឡាយដែលបណ្ឌិតតែងកំណត់វិនិច្ឆ័យបានថា ធម៌ទាំងនេះជាសង្ខតៈ (ឬអសង្ខតៈ) ដោយរូបនេះ ព្រោះហេតុនោះ រូបដែលកំណត់វិនិច្ឆ័យបាននោះ ឈ្មោះថា លក្ខណៈ បានដល់ លក្ខណៈរបស់និប្ផន្នរូប។

លក្ខណៈទូទៅរបស់នាមរូបមាន៣ យ៉ាងគឺ **ឧបាទៈ** ការកើតឡើង **ឋិតិ** ការតាំងនៅ **ភង្គៈ** ការបែកធ្លាយ។ រូបទាំង៣នេះបង្ហាញអនុខណៈក្នុងរូបធម៌ ហៅថា លក្ខណរូប។

១.**ឧបច្ចយ** ការកើតឡើងនៃរូប ក្នុងខណៈបដិសន្ធិ និងការកើតឡើងបន្តរបស់រូប រហូតដល់រូបដែលជាតម្រូវការក្នុងជីវិតមានទ្រង់ទ្រាយគ្រប់គ្រាន់

-Production

**ឧបចយរូប** មានការកើតឡើងគ្រាដំបូង ជាលក្ខណៈ

២.**សន្តតិរូប** ការកើតឡើងនៃរូប ជាបន្តបន្ទាប់ពេញមួយជីវិត ។ (Continuity)

**សន្តតិ** មានសេចក្តីចម្រើន ជាលក្ខណៈ

៣.**ជរតារូប** រូបដែលចម្រើនឡើងនិងទ្រុឌទ្រោមនៅក្នុងអំឡុងពេលកើតឡើង។ (Decay)

**ជរតារូប** មានការទុំជោរនៃរូប ជាលក្ខណៈ។

អាយុរបស់រូបមាន ៥១ អនុខណៈ (ខណៈតូច៣គុណនឹងខណៈធំ១៧) ខណៈទី១ រលត់ទៅ និង

ខណៈទី ៥១ ចំណែកនៅសល់ ៤៩ ខណៈជាខណៈដែលតាំងនៅ ឈ្មោះថា **ជរតារូប**។

## ជរាមាន ២ គឺ

១.**អវីចិជរា** ជរាដែលមិនមានប្រាកដ ឬ បដិច្ឆន្នជរា ជរាដែលបិទបាំង

២.**សវីចិជរា** ជរាដែលមានប្រាកដ ឬ អប្បដិច្ឆន្នជរា ជរាដែលមិនបិទបាំង

**៤.អនិច្ចតារូប** បានដល់ រូបកំពុងបែកធ្លាយ

-Impermanence

**អនិច្ចតារូប** មានការបែកធ្លាយ ជាលក្ខណៈ។

**ចំណាំៈ ឧបចយ** និង**សន្តតិ** ចាត់ជាជាតិ (ការកើត) បើនិយាយឱ្យហ្មត់ចត់ទៅលក្ខណរូបមានត្រឹមតែ៣ ប៉ុណ្ណោះ គឺ**ជាតិ ជរា អនិច្ចតា**។

(ចប់រូបន័យទី១ រូបសមុទ្ទេស)

VIDEO 20

## រូបន័យទី ២ រូបវិភាគន័យ

ការវិភាគទៅលើរូប ចែកជាពួកៗ មិនឱ្យច្របូកច្របល់គ្នាមាន២ពួក **១.ឯកវិធន័យ និងទុកន័យ**។

# ១.ឯកវិធន័យ

១.១ **អហេតុកៈ** រូបទាំងអស់ឥតមានហេតុ

១.២ **សប្បច្ចយៈ** រូបទាំងអស់ទាក់ទងនឹងបច្ច័យ (កម្ម ចិត្ត ឧតុ អាហារ)

១.៣ **សាសវៈ** រូបទាំងអស់ជាអារម្មណ៍របស់កិលេស

១.៤ **សង្ខតៈ** រូបទាំងអស់តាក់តែងឡើងដោយបច្ច័យ ៤

១.៥ **លោកិយ:** រូបទាំងអស់ទាក់ទងនឹងលោក ដែលជាលោកនៃឧបាទានក្ខន្ធ ៥

១.៦ **កាមាវចរ:** រូបទាំងអស់លិចចុះក្នុងលំដាប់ នៃកាមារម្មណ៍

១.៧ **អនារម្មណ:** រូបទាំងអស់មិនទទួលដឹងនូវ អារម្មណ៍

១.៨ **អប្បហាតព្វ:** រូបទាំងអស់រមែងមិនលះបង់ បានដោយមគ្គ។

## ២.ទុកន័យ

២.១ **អជ្ឈត្តិករូប ៥** រូបខាងក្នុង បានដល់ បសាទរូប ៥ ប្រៀបដូចមនុស្សក្នុងផ្ទះ **ពាហិររូប** រូបខាងក្រៅ បានដល់ រូប ២៣ ប្រៀបដូចមនុស្សក្រៅផ្ទះ។

២.២ **វត្ថុរូប ៦** រូបជាទីអាស្រ័យចិត្តនិងចេតសិក បានដល់ បសាទរូប ៥ ហទយរូប១ **អវត្ថុរូប** រូបមិនជាទីអាស្រ័យ បានដល់រូប ២២។

២.៣ **ទ្វាររូប ៧** រូបជាទ្វារ បានដល់ បសាទរូប ៥ វិញ្ញត្តិរូប ២ **អទ្វាររូប** បានដល់ រូប ២១។

២.៤ **ឥន្ទ្រិយរូប៨** រូបដែលជាធំ បានដល់ បសាទរូប ៥ ឥត្ថិន្ទ្រិយ១ បុរិសិន្ទ្រិយ១ ជីវិតរូប១ **អនិន្ទ្រិយរូប** បានដល់ រូប ២០។

២.៥ **ឱឡារិករូប១២** រូបគ្រោតគ្រាត បានដល់ បសាទរូប ៥ វិសយរូប ៧ **សុខុមរូប** រូបល្អិត មាន ១៦។

២.៦ **សន្តិកេរូប១២** រូបជិត បានដល់ បសាទរូប ៥ វិសយរូប ៧ **ទូរេរូប** រូបឆ្ងាយ បានដល់រូប ១៦។

២.៧ **សប្បដិឃរូប១២** រូបប៉ះខ្ទប់ បានដល់ បសាទរូប ៥ វិសយរូប ៧ **អប្បដិឃរូប** រូបមិនប៉ះខ្ទប់នឹងគ្នាបាន មាន១៦។

២.៨ **ឧបាទិន្នរូប១៨** រូបដែលកើតពីអកុសលកម្មនិងលោកិយកុសលកម្ម បានដល់ កម្មជរូប ១៨ គឺ មហាភូតរូប៤ បសាទរូប៥ វណ្ណរូប១ គន្ធរូប១ រសរូប១ អាហាររូប១ ភាវរូប ២ ហទយរូប១ ជីវិតរូប ១ និង បរិច្ឆេទរូប ១ ចំណែករូបក្រៅនេះជា **អនុបាទិន្នរូប**។

២.៩ **សនិទស្សនរូប១** រូបដែលឃើញដោយភ្នែកបានដល់ រូបារម្មណ៍ គឺពណ៌ផ្សេងៗ អនិទស្សនរូប រូបដែលមិនអាចមើលឃើញ មាន ២៧។

២.១០ **គោចរគាហិករូប៥** រូបដែលអាចទទួលអារម្មណ៍បាន បានដល់ បសាទរូប ៥មាន២ យ៉ាង។

១.**អសម្បត្តគោចរគាហិករូប** = រូបដែលទទួលអារម្មណ៍ដែលមកមិនដល់ខ្លួន គឺចក្ខុបសាទ សោតបសាទ (ភ្នែកនិងត្រចៀកទទួលអារម្មណ៍ពីចម្ងាយបាន) ។

២.**សម្បត្តគោចរគាហិករូប** = រូបដែលទទួលអារម្មណ៍ដែលមកដល់ខ្លួន គឺឃានបសាទ ជិវ្ហាបសាទ កាយបសាទ (ក្លិន រស ផោដ្ឋព្វ ទាល់តែមកប៉ះខ្ទប់នឹងប្រសាទទាំង ៣) នៅសល់ ២៣ ទៀតជា **អគោចរគាហិករូប**។

២.១១ **អវិនិព្ភោគរូប៨** រូបដែលមិនបែកគ្នាបានដល់ មហាភូតរូប ៤ វណ្ណរូប១ គន្ធរូប១ រសរូប ១ អាហាររូប១ **វិនិព្ភោគរូប** រូបដែលបែកគ្នាបានមាន ២០។

ចប់រូបន័យទី ២ រូបវិភាគ

VIDEO 21

# រូបន័យទី ៣ រូបសមុដ្ឋាន

(ហេតុឱ្យកើតរូប)

## សមុដ្ឋាននៃរូប ៤ យ៉ាង

**១.អតីតកម្ម** បានដល់ ចេតនា ២៥

**២.ចិត្ត** បានដល់ ចិត្តុប្បាទ ៧៥ (វៀរចិត្ត១៤)

**៣.ឧតុ** បានដល់ ភាពក្តៅ និងភាពត្រជាក់

**៤.អាហារ** បានដល់ ឱជាដែលមាននៅទាំងខាងក្នុង ទាំងខាងក្រៅ

# អធិប្បាយសមុដ្ឋាន៤

## ១.កម្មសមុដ្ឋាន

កម្ម ២៥ គឺចេតនាក្នុងអកុសលចិត្ត ១២ មហាកុសលចិត្ត ៨ ក្នុងរូបាវចរកុសលចិត្ត៥ ដែលធ្វើរួចហើយក្នុងអតីតភពឬបច្ចុប្បន្នភព រមែងជាបច្ច័យកើតរូប។

រូបដែលកើតពីកម្មជាសមុដ្ឋានមាន ១៨ គឺមហាភូតរូប៤ ប្រសាទរូប ៥ គោរចរូប៣ (វៀរសទ្ទរូប) ភាវរូប២ ហទយរូប១ ជីវិតរូប១ អាហាររូប១ បរិច្ឆេទរូប១។

<u>ចំណាំ</u> អរូបាវចរកម្ម មិនបង្កើតរូបបានទេ។

## កម្មជរូបកើតបាន ២៧ ភូមិ

- **បញ្ចវោការភូមិ** (ភូមិដែលមានខន្ធ៥) កើតបាន២៦ ភូមិ
- **ឯកវោការភូមិ** (ភូមិដែលមានខន្ធ១) កើតបាន ១ ភូមិ។

VIDEO 22

## ២.ចិត្តសមុដ្ឋាន

ចិត្ត ៧៥ (វៀរទ្វិបញ្ចវិញ្ញាណ១០ និងអរូបាវចរវិបាកចិត្ត៤) រមែងបង្កើតនូវរូបបាន។ ចំណែកឯបដិសន្ធិ

ចិត្តទាំងអស់ និងចុតិរបស់ព្រះអរហន្ត រមែងបង្កើតរូបមិនបាន។

## ចិត្តជរូបមាន ៧

១.**ចិត្តជរូប ដែលជាសាមញ្ញ** គឺប្រព្រឹត្តទៅតាមធម្មតាក្នុងរាងកាយ ដូចជាដកដង្ហើមចេញចូល ការលោតរបស់បេះដូងជាដើម គឺអវិនិព្ភោគរូប៨។

ចិត្តដែលធ្វើឱ្យចិត្តជរូបសាមញ្ញកើតមាន ៧៥ គឺ អកុសលចិត្ត១២ អហេតុកចិត្ត៨ (វៀរទ្វិបញ្ចវិញ្ញាណ១០) កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៣ (វៀរវិបាកចិត្ត៤) លោកុត្តរចិត្ត៨។

២.ចិត្តផ្សរូប ដែលជាប់ទាក់ទងជាមួយការសើច បានដល់ ១៣ គឺ សោមនស្សលោភមូលចិត្ត ៤ សោមនស្សមហាកុសលចិត្ត ៤ សោមនស្សមហា-កិរិយាចិត្ត ៤ សោមនស្សហសិតុប្បាទចិត្ត១។

## ការសើចឬញញឹមរបស់បុគ្គលផ្សេងៗ

- ❖ បុថុជ្ជនញញឹមឬសើចដោយចិត្ត ៨ ដួង គឺ សោមនស្សលោភមូលចិត្ត ៤ សោមនស្ស មហាកុសលចិត្ត៤។
- ❖ ព្រះសេក្ខបុគ្គលញញឹមឬសើចដោយចិត្ត ៦ ដួង គឺ សោមនស្សលោភមូលចិត្ត ទិដ្ឋិគតវិប្ប យុត្តចិត្ត ២ សោមនស្សមហាកុសលចិត្ត ៤។

❖ ព្រះអសេក្ខបុគ្គលញញឹមឬសើចដោយចិត្ត ៥ ដួង សោមនស្សមហាកិរិយាចិត្ត ៤ សោមនស្សហសិតុប្បាទចិត្ត ១។

៣.**ចិត្តជូររូប ដែលជាប់ទាក់ទងនឹងការយំ** បានដល់ទោសមូលចិត្ត ២ ។

៤.**ចិត្តជូររូប ដែលជាប់ទាក់ទងនឹងការកម្រើកញ័រ** បានដល់ ចិត្តដែលធ្វើឱ្យមានការកម្រើកផ្សេងៗ ដោយឥរិយាបថតូច មានការបត់ចូល ការលា ឱន ងើប ក្រឡេកឆ្វេង ស្តាំ ដើរ ទៅមុខ ថយក្រោយ ប៉ប្រិចភ្នែក ស្វាប ជាដើម ដោយចិត្ត ៣២គឺ

❖ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២ ។

**៥.ចិត្តជរូប ដែលជាប់ទាក់ទងនឹងការនិយាយ** បានដល់ ការបញ្ចេញសំឡេងអំពីមាត់កើតដោយចិត្ត ៣២ ដូចខទី៤ ដែរ។

**៦.ចិត្តជរូប ដែលជាប់ទាក់ទងជាមួយឥរិយាបថធំ៤** បានដល់ ការកម្រើកនៃឥរិយាបថធំ៤ គឺ ដេក ដើរ ឈរ អង្គុយ កើតដោយចិត្ត ៣២ ដែរ។

**៧.ចិត្តជរូប ដែលជាប់ទាក់ទងជាមួយឥរិយាបថ៤** ដែលតាំងមាំ បានដល់ ឥរិយាបថតាមប្រក្រតីរបស់

អ្នកមិនមានរោគភ័យ បៀតបៀនកើតដោយចិត្ត ៥៨ គឺ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២ អប្បនាជវនចិត្ត ២៦។

VIDEO 23

## ៣.ឧតុសមុដ្ឋាន

**ឧតុ** បានដល់ តេជោធាតុ ដែលជាសីតតេជោ (ភាពត្រជាក់ ឧណ្ហភាពក្តៅ ដែលជាសមុដ្ឋាន មានពេញទូទៅក្នុងរាងកាយរបស់សត្វ និងមានទូទៅខាងក្រៅពីសត្វ។

**ឧតុជរូប**គឺ រូបដែលកើតអំពីឧតុមាន១៣ រូប គឺ មហាភូតរូប ៤ គោចររូប ៤ អាហាររូប ១ បរិច្ឆេទរូប១ វិការរូប ៣។

VIDEO 24

## ៤.អាហារសមុដ្ឋាន

ចំណីអាហារ ,ឱជារមែងប្រាកដក្នុងរូបកលាបទាំងអស់ ទាំងក្នុងកាយក្រៅកាយ។ អាហារខាងក្រៅបរិភោគចូលទៅរមែងរលាយក្នុងក្រពះ និងជ្រួតជ្រាបទៅតាមឈាមគ្រប់ផ្នែកទាំងអស់នៃកាយ។ ដូច្នោះហើយ បានជាឱជាដែលនៅខាងក្នុងនិងឱជាដែលនៅខាងក្រៅនោះ ជួបគ្នាគ្រប់ផ្នែកនៃរាងកាយ

នោះ។ ឱជានៅខាងក្នុងសត្វហៅថា **អជ្ឈត្តឱជា** នៅខាងក្រៅហៅថា **ពហិទ្ធឱជា**។ **អជ្ឈត្តឱជា** ជាកម្មជឱជា ក្នុងកម្មជរូប១៨។ នៅខាងក្រៅជា **ពហិទ្ធឱជា** ក្នុងអវិនិព្ភោគរូប៨ ពេលសត្វបរិភោគអាចរស់នៅផ្សំជាមួយកម្មជឱជាអាចរស់នៅរហូតបាន៧ថ្ងៃ។

## អាហារជរូបមាន ១២ គឺ

មហាភូតរូប ៤ គោចររូប ៣ (វៀរសទ្ទរូប) អាហាររូប ១ បរិច្ឆេទរូប១ វិការរូប៣។

# រូបកើតពីសមុដ្ឋាន ៤

| សមុដ្ឋាន ៤ | ចំនួនរូប |
|---|---|
| **កម្មជរូប** កើតពីកម្ម | ១៨ |
| **ចិត្តជរូប** កើតពីចិត្ត | ១៥ |
| **ឧតុជរូប** កើតពីឧតុ | ១៣ |
| **អាហារជរូប** កើតពីអាហារ | ១២ |

## សម្តែងរូបសមុដ្ឋាន

## ប្រាកដនិងមិនប្រាកដ

## ១.កម្មជរូប ១៨

**ដោយប្រាកដ** មានរូប ៩ គឺ បសាទរូប៥ ភាវរូប ២ ជីវិតរូប ១ ហទយរូប១

**ដោយមិនប្រាកដ** មានរូប ៩ គឺ មហាភូតរូប៤ គោចររូប ៣ (វៀរសទ្ទរូប) អាហាររូប១ បរិច្ឆេទរូប១។

## ២.ចិត្តជរូប ១៥

**ដោយប្រាកដ** មានរូប២ គឺ វិញ្ញត្តិរូប ២

**ដោយមិនប្រាកដ** មានរូប ១៣ គឺអវិនិព្ភោគរូប ៨ សទ្ទរូប១ បរិច្ឆេទរូប១ វិការរូប ៣។

## ៣.ឧតុជរូប ១៣

**ដោយប្រាកដ** មិនមាន

**ដោយមិនប្រាកដ** មានរូប ១៣ គឺអវិនិព្ភោគរូប ៨ សទ្ទរូប១ បរិច្ឆេទរូប១ វិការរូប ៣។

## ៤.អាហាររូប ១២

**ដោយប្រាកដ** មិនមាន

**ដោយមិនប្រាកដ** មានរូប ១២ គឺអវិនិព្ភោគរូប ៨ សទ្ទរូប១ វិការរូប ៣។

## ប្រភេទហេតុនៃការកើតរូប

១.**ឯកហេតុរូប** = រូបកើតដោយហេតុ១

២.**ទ្វិជរូប** = រូបកើតដោយហេតុ ២

៣.**តិជរូប** = រូបកើតដោយហេតុ ៣

៤.**ចតុជរូប** = រូបកើតដោយហេតុ ៤

៥.**នកុតោចិរូប** = រូបមិនកើតពីសមុដ្ឋាន៤

## ឯកជរូប ១១

១.បសាទរូប ៥ ភាវរូប ២ ហទយរូប១ ជីវិតរូប ១ រូប៩ នេះ កើតពីកម្មតែម្យ៉ាង។

វិញ្ញត្តិរូប ២ កើតពីចិត្តតែម្យ៉ាង។

## ទ្វិជរូប ១

២.**សទ្ទ** (សំឡេង) កើតពីចិត្ត និងឧតុ។ **សំឡេងវាចា** ដូចជាការនិយាយ សើច យំ ថ្ងូរ ច្រៀង ការហួចជាដើមកើតពីចិត្ត។ ឯសំឡេងអវាចា ដូចសូររន្ទះ សូរតន្ត្រីពីឧបករណ៍ សូរពីវិទ្យុ ចម្រៀងពីកាសែត សូរឡានជាដើម កើតពីឧតុ។

## តិជរូប ១

៣.**តិជរូប** មាន ៣ យ៉ាង គឺ **រូបស្ស លហុតា រូបស្ស មុទុតា រូបស្ស កម្មញ្ញតា** វិការរូប៣ នេះកើតពីចិត្ត ឧតុ និងអាហារ។ រូបទាំងនេះទទួលអារម្មណ៍សម្រាប់រីករាយ កាលដែលចិត្តរបស់យើងស្រឡះល្អ ឬកាលដែលអាកាសធាតុស្រស់ល្អ ឬក្រោយពីយើងបរិភោគអាហារជាទីរីករាយ។

## ចតុជរូប ៩

៤.**ចតុជរូប** មាន ៩ រូប រមែងកើតឡើងដោយហេតុ ៤ ទាំងអស់។ ចតុជរូប ៩ គឺ អវិនិព្ភោគរូប ៨

អាកាសធាតុ១ រមែងកើតឡើងនៅពេលដែលរូបកលាបរបស់អវិនិព្ភោគរូបកើតឡើង។

## នក្ខោចិរូប ៤

៥.**នកុតោចិ** មាន ៤ រូប គឺលក្ខណរូប ៤ មានឧបចយរូប សន្តតិរូបជាដើម។

## តារាងសមុដ្ឋានរូប

| ចំនួន | កម្ម | ចិត្ត | ឧតុ | អាហារ | សមុដ្ឋាន |
|---|---|---|---|---|---|
| មហាភូតរូប៤ | ៤ | ៤ | ៤ | ៤ | ៤ |
| បសាទរូប៥ | ៥ | - | - | - | កម្ម ១ |
| គោចររូប៣ | ៣ | ៣ | ៣ | ៣ | សមុដ្ឋាន ៤ |
| សទ្ទរូប១ | - | ១ | ១ | - | ចិត្ត ឧតុ ២ |
| ភាវរូប២ | ២ | - | - | - | កម្ម ១ |

| | | | | | |
|---|---|---|---|---|---|
| ហទយរូប១ | ១ | - | - | - | កម្ម ១ |
| ជីវិតរូប១ | ១ | - | - | - | កម្ម ១ |
| អាហាររូប១ | ១ | ១ | ១ | ១ | សមុដ្ឋាន ៤ |
| បរិច្ឆេទរូប១ | ១ | ១ | ១ | ១ | សមុដ្ឋាន ៤ |
| វិញ្ញត្តិរូប២ | - | ២ | - | - | ចិត្ត ១ |
| លក្ខណរូប៤ | - | - | - | - | មិនមាន |
| សរុបរូប ២៨ | ១៨ | ១៥ | ១៣ | ១២ | ➡ ៥៨/ ២៦ |

## ចែកកោដ្ឋាសរូប ៤២ តាមសមុដ្ឋានិករូប

**១.សសម្ភារបឋវី** ២០ កោដ្ឋាស

**២.សសម្ភារអាបោ** ១២ កោដ្ឋាស

**៣.សសម្ភារតេជោ** ៤ កោដ្ឋាស

**៤.សសម្ភារវាយោ** ៦ កោដ្ឋាស

| ១.សសម្ភារបឋវី ២០ | |
|---|---|
| ឧតុសមុដ្ឋាន | **ឧទរិយ** អាហារថ្មី **ករីស** អាហារចាស់ |
| មានសមុដ្ឋាន ៤ | **កេសា** សក់ **លោមា** រោម **នខា** ក្រចក **ទន្តា** ធ្មេញ **តចោ** ស្បែក **មំសំ** សាច់ **នហារូ** សរសៃ **អដ្ឋិ** ឆ្អឹង **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង **វក្កំ** តម្រងបស្សាវៈ **ហទយំ** បេះដូង **យកនំ** ថ្លើម **កិលោមកំ** វាវ **បិហកំ** ក្រពះ **បប្ផាសំ** សួត **អន្តំ** |

| | |
|---|---|
| | ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **មង្គលុង្គំ** ខួរក្នុងក្បាល។ |

## ២.សសម្ភារអាបោ ១២ កោដ្ឋាស

| | |
|---|---|
| ឧតុសមុដ្ឋាន | បុព្វោ ខ្ទុះ មុត្តំ មូត្រ |
| ចិត្ត ឧតុ សមុដ្ឋាន | **សេទោ** ញើស **អស្សុ** ទឹកភ្នែក **ខេឡោ** ទឹកមាត់ **សិង្ឃានិកា** ទឹកសំបោរ |
| មានសមុដ្ឋាន ៤ | **បិត្តំ** ទឹកប្រមាត់ **សេម្ហំ** ស្លេស្ម **វសា** ខ្លាញ់រាវ **លោហិតំ** ឈាម |

| | |
|---|---|
| | **លសិកា** ទឹករំអិល **មេទោ** ខ្លាញ់ខាប់ |

## ៣.សសម្ភារតេជោ ៤ កោដ្ឋាស

| កម្មសមុដ្ឋាន | បាចកតេជោ |
|---|---|
| សមុដ្ឋាន ៤ | ឧស្មាតេជោ ជីរណតេជោ សន្តាបនតេជោ |

# ៤.សសម្ភារវាយោ ៦ កោដ្ឋាស

| ចិត្តសមុដ្ឋាន | អស្សាសបស្សាស |
|---|---|
| សមុដ្ឋាន ៤ | ឧទ្ធង្គមវាយោ អធោគមវាយោ កុច្ឆិយវាយោ កោដ្ឋាសយវាយោ អង្គមង្គានុសារិវាយោ |

# សរុបសមុដ្ឋាន ៤ ក្នុងកោដ្ឋាស

| | |
|---|---|
| កម្មសមុដ្ឋាន | ១ |
| ចិត្តសមុដ្ឋាន | ១ |
| ឧតុសមុដ្ឋាន | ៤ |
| ចិត្តនិងឧតុសមុដ្ឋាន | ៤ |
| សមុដ្ឋាន ៤ | ៣២ |
| សរុបកោដ្ឋាស | ៤២ |

(ចប់ រូបន័យទី ៣ សមុដ្ឋានរូប)

VIDEO 25

# រូបន័យទី ៤ រូបកលាប

## (សំណុំនៃរូប)

រូប ២៨ ប្រភេទ តាមធម្មជាតិមិនកើតឡើងដោយបែកគ្នាទេ រមែងកើតឡើងដោយហេតុ ៤ តាមទម្រង់ជាសំណុំរូបតូចៗ ហៅថា កលាប។

## កលាបនោះមានលក្ខណៈ ៤ យ៉ាង

១.រូបទាំងអស់ក្នុងកលាបៈ រមែងកើតឡើងព្រមគ្នា

២.រូបទាំងនោះក៏ឈប់ឬរលត់ព្រមគ្នា គឺមានការរលត់ជាមួយគ្នា

៣.រូបទាំងអស់នោះអាស្រ័យមហាភូតរូប ៤ ទើបប្រាកដក្នុងកលាប

៤.រូបទាំងនោះ លាយចូលគ្នាយ៉ាងហ្មត់ចត់ណាស់ ទើបមិនអាចវែកញែកបាន គឺរូបទាំងនោះកើតរួមគ្នា។

**ចំណាំថា៖** កលាបគឺជាសំណុំរូបដ៏តូចពន់ពេក ទើបមិនអាចមើលឃើញបានទេ ទោះបីជានៅក្រោមអតិសុខុមទស្សន៍អេឡិចត្រូនិចក៏ដោយ។

កលាបមាន ២១ គឺ កម្មជ្ជកលាប ៩ ចិត្តជ្ជកលាប៦ ឧតុជ្ជកលាប ៤ អាហារជ្ជកលាប ២។

## កម្មជកលាប ៩

កម្មជ្ជកលាបទាំងនេះ រមែងកើតពីកម្មជ្ជរូប១៨។ កម្មជ្ជរូបទាំងអស់ផ្ទុកជីវិតរូប ដែលជាជីវិតរបស់រូបកាយ។

**១.ចក្ខុទសកកលាប** ក្រុមនៃចក្ខុបសាទមានរូប ១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១ ចក្ខុបសាទរូប ១

**២.សោតទសកកលាប** ក្រុមនៃសោតបសាទ មានរូប១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប១ សោតបសាទរូប ១

**៣.ឃានទសកកលាប** ក្រុមនៃឃានបសាទមានរូប១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១ ឃានបសាទ ១

**៤.ជិវ្ហាទសកកលាប** ក្រុមនៃជិវ្ហាបសាទមានរូប ១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១ ជិវ្ហាបសាទរូប ១

**៥.កាយទសកកលាប** ក្រុមនៃកាយបសាទមានរូប១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១ កាយបសាទ ១

**៦.ឥត្ថីភាវទសកកលាប** ក្រុមនៃភាពជាស្ត្រីមានរូប១០គឺអវិនិព្ភោគរូប៨ ជីវិតរូប១ ឥត្ថីភាវរូប ១

**៧.បុរិសភាវទសកកលាប** ក្រុមនៃភាពជាប្រុសមានរូប១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១ បុរិសភាវរូប ១

**៨.វត្ថុទសកកលាប** ក្រុមនៃវត្ថុមានរូប១០ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១ ហទយវត្ថុ ១

**៩.ជីវិតនវកកលាប** ក្រុមនៃជីវិតមានរូប ៩ គឺអវិនិព្ភោគរូប ៨ ជីវិតរូប ១។

**អវិនិព្ភោគរូប** រូបមិនបែកអំពីគ្នា មាន ៨ គឺបឋវី អាបោ តេជោ វាយោ វណ្ណៈ គន្ធ រសៈ និងឱជា។ រូប ៨ នេះ មាននៅប្រចាំក្នុងសមុដ្ឋានទាំង ៤ ទើបឈ្មោះថា សុទ្ធដ្ឋកកលាប។

## កម្មជកលាបចែកជា ៣ ចំណែក

**១.ឧបរិមកាយ** កាយខាងលើ តាំងពីករហូតដល់ក្បាល មានកម្មជ្ជកលាប ៧ គឺ ចក្ខុទសកកលាប សោតទសកកលាប ឃានទសកកលាប ជិវ្ហាទសកកលាប កាយទសកកលាប ភាវទសកកលាប ជីវិតនវកកលាប

**២.មជ្ឈិមកាយ** កាយកណ្តាល តាំងពីកចុះដល់ផ្ចិត មានកម្មជកលាប ៤ គឺ កាយទសកកលាប វត្ថុទសកកលាប ភាវទសកកលាប ជីវិតនវកកលាប

**៣.ហេដ្ឋិមកាយ** កាយខាងក្រោម តាំងពីផ្ចិតចុះដល់ជើង មានកម្មជកលាប ៣ គឺ កាយទសកកលាប ភាវទសកកលាប ជីវិតនវកកលាប។

## ២.ចិត្តជកលាប ៦

**១.សុទ្ធដ្ឋកកលាប** ក្រុមរូប ៨ គឺអវិនិព្ភោគរូប ៨ កើតនៅពេលមិនមានការកម្រើកញ័រនៃកាយ ឬមិនបាននិយាយបញ្ចេញសំឡេងមកខ្លះ មានត្រឹមតែ

អាការដេកដង្ហើមចេញ ចូល ឬមុខស្លក់ មុខក្រហម បើវេលាក្រោធមានមុខគួរស្អប់ជាដើម។

**២.កាយវិញ្ញត្តិនវកកលាប** ក្រុមរូប៩ គឺ អវិនិព្ភោគរូប៨ កាយវិញ្ញត្តិរូប ១ រូបទាំងនេះធ្វើឱ្យកម្រើកកាយក្នុងឥរិយាបថផ្សេងៗ មានការដេក ដើរ ជាដើម។

**៣.វចីវិញ្ញត្តិសទ្ទទសកកលាប** ក្រុមរូប១០ គឺ អវិនិព្ភោគរូប ៨ សទ្ទរូប១ វចីវិញ្ញត្តិរូប១ ជារូបដែលកើត ក្នុងវេលានិយាយ ច្រៀង សូធ្យធម៌ អានសៀវភៅធម៌ជាដើម។

**៤.លហុតាទិឯកាទសកកលាប** ក្រុមរូប១១ គឺ អវិនិព្ភោគរូប ៨ វិការរូប ៣ រូបនេះកើតឡើងក្នុង ខណៈដែលមិនមានការកម្រើកកាយ និងវាចា។

**៥.កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប** ក្រុមរូប ១២ គឺ អវិនិព្ភោគរូប ៨ កាយវិញ្ញត្តិរូប១ វិការរូប ៣ រូបនេះកើតឡើងក្នុងវេលាកម្រើកញ័រនៃ កាយ មានអាការផ្សេងៗជារូបសមគួរដល់ការងារ។

**៦.វចីវិញ្ញត្តិសទ្ទលហុតាទិតេរសក កលាប** ក្រុមរូប ១៣ គឺអវិនិព្ភោគរូប ៨ វចីវិញ្ញត្តិរូប ១ សទ្ទរូប១ វិការរូប៣ រូបនេះកើតក្នុងខណៈកម្រើក

ញ៉ុំរវាចាគួរដល់ការងារ ព្រមនឹងសំឡេងដែលកើតឡើង ។

**បុ.ចិត្តជរូប និងចិត្តជកលាបខុសគ្នាដូចម្ដេច?**

**វិ.ចិត្តជរូប** រូបកើតពីចិត្តមាន ១៥ រូប ឯចំណែកចិត្តជកលាបមាន ១៤ រូប (រៀរបរិច្ឆេទរូប)។

ចិត្តជរូបនិងចិត្តជកលាប កើតបានចំពោះសត្វដែលមានខន្ធ ៥ និងកើតបានចិត្ត ៧៥ ចែកជា៣ ប្រភេទ

**១.ចិត្តកលាប** ដែលឈ្មោះថា សុទ្ធដ្ឋកកលាបកើតបានពីចិត្ត ៧៥។

២.**ចិត្តជកលាប** ដែលឈ្មោះថា **សទ្ទនវកកលាប កាយវិញ្ញត្តិនវកកលាប វចីវិញ្ញត្តិសទ្ទទសកកលាប សទ្ទលហុតាទិទ្វាទសកកលាប កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប វចីវិញ្ញត្តិសទ្ទលហុតាទិតេរសកកលាប** កើតពីចិត្ត ៣២ គឺ

- មនោទ្វារាវជ្ជនចិត្ត ១
- កាមជវនចិត្ត ២៩
- អភិញ្ញាចិត្ត ២ ។

៣.**ចិត្តជកលាប** ដែលឈ្មោះថា **លហុតាទិឯកាទសកកលាប** កើតពីចិត្ត ៥៨ គឺ

❖ មនោទ្វារាវជ្ជនចិត្ត ១

❖ កាមជវនចិត្ត ២៩

❖ អភិញ្ញាចិត្ត ២[១]

❖ អប្បនាជវន ២៦។

## ឋានរបស់ចិត្តជួកលាប ៦

## ក្នុងកាយ ៣ ចំណែក

[១] អភិញ្ញាចិត្ត ២ កុសលនិងកិរិយាក្នុងបញ្ចមជ្ឈាន។ អភិញ្ញាមាន៦ គឺ១.ឥទ្ធិវិធ ២.ទិព្វសោត ៣.ចេតោបរិយញ្ញាណ ៤.បុព្វនិវាសញ្ញាណ ៥.ទិព្វចក្ខុ ៦.អាសវក្ខយញ្ញាណ។

**១.ក្នុងឧបរិមកាយ** កាយខាងលើមានទាំង ៦ កលាប គឺ កាយវិញ្ញត្តិនវកកលាបជាដើម។

**២.មជ្ឈិមកាយ** កាយកណ្តាល មានចិត្តជ្ជកលាប ៤ គឺ សុទ្ធដ្ឋកកលាប ១ កាយវិញ្ញត្តិនវកកលាប១ លហុតាទិឯកាទសកកលាប១ កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប១។

**៣.ហេដ្ឋិមកាយ** កាយចំណែកក្រោម មានកលាប៤ ដូចទី២ ដែរ។

# ៣.ឧតុជកលាប

(សំណុំនៃឧតុ)

## កើតក្នុងកាយសត្វមាន ៤

**១.សុទ្ធដ្ឋកកលាប** ក្រុមរូប៨ រូប គឺអវិនិព្ភោគរូប ៨ មានទាំងក្នុង និងខាងក្រៅ។ ចំពោះកាយរបស់សត្វដែលមានខន្ធ៥ ព្រោះជាផ្ទៃឋានឱ្យកលាបដទៃៗកើតឡើង។ សុទ្ធដ្ឋកកលាប ខាងក្រៅ ដូចដើមឈើ មានភ្នំជាដើម។

**២.សទ្ទនវកកលាប** ក្រុមនៃសទ្ទមាន ៩ រូប គឺ អវិនិព្ភោគ ៨ សទ្ទរូប១។ កើតក្នុងកាយនិងខាង

ក្រៅ កើតក្នុងវត្ថុមានជីវិតនិងមិនមានជីវិត ដូចដើមឈើ ភ្នំជាដើម។ ក្នុងកាយសត្វដែលមិនជាប់ទាក់ទងជាមួយ ការបញ្ចេញសំឡេង ដូចជាកូពោះ សំឡេងស្រមុក សំឡេងទះដៃជាដើម។

**៣.លហុតាទិឯកាទសកកលាប** ក្រុមនៃវិការរូបមាន ១១ គឺអវិនិព្ភោគរូប ៨ វិការរូប ៣ កើតជាមួយសត្វដែលមានជីវិតប៉ុណ្ណោះ មិនកើតក្នុងវត្ថុខាងក្រៅទេ។

**៤.សទ្ទលហុតាទិទ្វាទសកកលាប** ក្រុមនៃអវិនិព្ភោគរូប ៨ សទ្ទរូប១ វិការរូប ៣ កើតខាងក្នុង

កាយ សត្វប៉ុណ្ណោះ មិនជាប់ទាក់ទងជាមួយនឹងការបញ្ចេញ សំឡេង ការអានសៀវភៅ ដូចជាសំឡេងស្រមុក សំឡេងទះដៃ និងសំឡេងទះតប់ជាដើម។

## ឧតុជកលាប ២ កើតខាងក្រៅ

**១.សុទ្ធដ្ឋកកលាប** ក្រុមនៃ អវិនិព្ភោគរូប ៨ ដែលមាននៅក្នុងលោក ដូចក្នុងផែនដី ភ្នំ ដើមឈើ ទន្លេ ភ្លើង ខ្យល់ ព្រះអាទិត្យ ព្រះចន្ទជាដើម។

**២.សទ្ទនវកកលាប** ក្រុមនៃសទ្ទរូប១ អវិនិព្ភោគរូប៨ ដូចសំឡេងខ្យល់បក់ ផ្គរលាន់ សំឡេងទឹកហូរ សំឡេងរថ សំឡេងទូកជាដើម។

# ឋានរបស់ឧតុជរូបក្នុង

# កាយ ៣ ចំណែក

**ឧបរិមកាយ មជ្ឈិមកាយ ហេដ្ឋិមកាយ** ឧតុជកលាប កើតបានទាំង៤ក្នុងរាងកាយមនុស្សទូទៅ។ ចំពោះ សុទ្ធដ្ឋកកលាប និងលហុតាទិឯកាទសកកលាប នៅជាប្រចាំថ្ងៃ។ ចំពោះសទ្ទនវកកលាប និងសទ្ទ លហុតាទិទ្វាទសកកលាប មិនកើតជាប្រចាំទេ កើត គ្រាខ្លះប៉ុណ្ណោះ។

# ឧតុជរូបកលាប ៤ យ៉ាង

**១.កម្មប្បច្ចយឧតុជរូបកលាប** បានដល់ ឧតុជរូបកលាបដែលមានកម្មជាបច្ច័យ

**២.ចិត្តប្បច្ចយឧតុជរូបកលាប** បានដល់ ឧតុជរូបកលាប ដែលមានចិត្តជាបច្ច័យ

**៣.ឧតុប្បច្ចយឧតុជរូបកលាប** បានដល់ ឧតុជរូបកលាប ដែលមានឧតុជាបច្ច័យ

**៤.អាហារប្បច្ចយឧតុជរូបកលាប** បានដល់ ឧតុជរូបកលាបដែលមានអាហារជាបច្ច័យ។

## ៤.អាហារជកលាប ២

**១.សុទ្ធដ្ឋកកលាប** ក្រុមនៃរូប ៨ កាលសត្វបរិភោគអាហារណាៗ ចូលទៅហើយ សូម្បីវត្ថុនោះៗ ជាថ្នាំក៏ដោយ បើធ្វើឱ្យរាងកាយមិនសប្បាយ មិនវាងវៃ មិនរឹងមាំ មិនគួរដល់ការងារ ក៏ត្រឹមអវិញ្ញោគរូប៨។

**២.លហុតាទិឯកាទសកកលាប** ក្រុមនៃវិការរូប មាន១១ កាលសត្វបរិភោគវត្ថុណាៗ ចូលទៅហើយ សូម្បីជាថ្នាំក៏ដោយ បើធ្វើឱ្យរាងកាយសប្បាយ វាងវៃ រឹងមាំ គួរដល់ការងារ មានវិការរូប៣កើតរួមផង។

ឋាននៃអាហារ ២ ក្នុងកាយ ៣ចំណែក អាហារជ្ជ-កលាបប្រព្រឹត្តក្នុងកាយបានទាំង៣ ចំណែក។

## កលាប ២១ ក្នុងអាការ ៤២

កលាបកើតពីកម្មមាន ៩ កើតពីចិត្តមាន ៦ កើតពីឧតុមាន ៤ កើតពីអាហារមាន២។

## ១.សសម្ភារបឋវី ២០ មាន ២ ន័យ

| | | |
|---|---|---|
| ១.ឧតុ | **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ គឺអវិនិព្ភោគរូប ៨ | |
| | កាយទសកកលាប ១០ | |

<table>
<tr><td rowspan="4">២.សមុដ្ឋាន ៤ រូប ៥ កលាប<br>មានរូប ៤៤</td><td>ភាវទសកកលាប ១០</td><td>កម្មជ កលាប</td></tr>
<tr><td colspan="2">ចិត្តសុទ្ធដ្ឋកកលាប ៨</td></tr>
<tr><td colspan="2">ឧតុសុទ្ធដ្ឋកកលាប ៨</td></tr>
<tr><td colspan="2">អាហារសុទ្ធដ្ឋកកលាប ៨</td></tr>
</table>

# ២.សសម្ភារអាចោ ១២ មាន ៣ ន័យ

| | |
|---|---|
| ១.សមុដ្ឋាន៤ | អាការ ៦ គឺបិត្តំ សេម្ហំ លោហិតំ មេទោ វសា លសិកា |
| ២.ចិត្ត និងឧតុ | អាការ ៤ គឺ សេទោ អស្សុ ខេឡោ សង្ឃាណិកា |
| ៣.ឧតុ | អាការ ២ គឺ បុព្វោ មុត្តំ |

# ៣.សសម្ភារតេជោ ៤ មាន ២ ន័យ

| | |
|---|---|
| ១.សមុដ្ឋាន៤ អាការ ៣ គឺ ឧស្មា ជីរណ សន្តាបនមាន រូប ៣៣ | ជីវិតនវកកលាប ១ រូប ៩ (កម្ម) |
| | ចិត្តសុទ្ធដ្ឋកកលាប១ រូប ៨ |
| | ឧតុសុទ្ធដ្ឋកកលាប១ រូប ៨ |
| | អាហារសុទ្ធដ្ឋកកលាប១ រូប ៨ |
| ២.កម្ម | អាការ ១ បាចកតេជោ ១ មាន កលាប១ គឺជីវិតនវកកលាប |

## ៤.សសម្ភារវាយោ ៦ មាន ២ ន័យ

| | |
|---|---|
| ១.សមុដ្ឋាន៤ មាន ៤ កលាប | ឧទ្ធង្គមវាយោ អធោគមវាយោ កុច្ឆិយវាយោ កោដ្ឋាសយវាយោ អង្គមង្គានុសារិយវាយោ |
| ២.ចិត្ត មាន១ កលាប | អស្សាសបស្សាសវាយោ |

## រូបកលាប ២១ ក្នុងសសម្ភាររូប ៥

## រូបដែលកើតពីកម្ម ចិត្ត ឧតុ អាហារជាសមុដ្ឋាន

១.ចក្ខុសសម្ភារៈ មានរូបកលាបកើត៦ រាប់ជារូបបាន ៥៤ គឺ

**ចក្ខុទសកកលាប** ១ មានរូប១០ កើតពីកម្ម

**ភាវទសកកលាប** ១ មានរូប១០ កើតពីកម្ម

**កាយទសកកលាប** ១ មានរូប១០ កើតពីកម្ម

**ចិត្តសុទ្ធដ្ឋកកលាប** ១ មានរូប៨ កើតពីចិត្ត

**ឧតុសុទ្ធដ្ឋកកលាប** ១ មានរូប៨ កើតពីឧតុ

**អាហារសុទ្ធដ្ឋកកលាប** ១ មានរូប៨ កើតពីអាហារ

**២.សោតសសម្ភារៈ** មាន ៦ កលាប មាន៥៤ រូប

**៣.ឃានសសម្ភារៈ** មាន ៦ មាន៥៤ រូប

**៤.ជិវ្ហាសសម្ភារៈ** មាន៦ មាន៥៤ រូបដូចគ្នាចក្ខុសសម្ភារៈដែរ

**៥.កាយសសម្ភារៈ** មានរូបកលាប ៥ បាន ៤៤ដូចគ្នានឹងទី១ ដែរ តែវៀរចក្ខុប្រសាទ សោតប្រសាទ ឃានប្រសាទ ជិវ្ហាប្រសាទ មានតែកាយប្រសាទ ព្រោះកាយសសម្ភារៈមិនមានចក្ខុ សោត ឃាន និង ជិវ្ហាប្រសាទ តែក្នុងចក្ខុសសម្ភារៈ សោតសសម្ភារៈ

ឃានសសម្ភារៈ ជិវ្ហាសសម្ភារៈ មានកាយប្រសាទកើតរួមផង។

## កលាបខាងក្នុងនិងខាងក្រៅ

រូបកលាបទាំងអស់ ២១ ខាងលើ រមែងកើតខាងក្នុងកាយសព្វសត្វ។ ឥត្ថីភាវទសកកលាប មិនកើតឡើងក្នុងបុរស ទាំងបុរិសភាវទសកៈក៏ដូចគ្នា មិនកើតឡើងក្នុងស្ត្រី។ ចំពោះបុគ្គលទាំងឡាយណាដែលកើតមកខ្វាក់ភ្នែកឬថ្លង់ រមែងបាត់ចក្ខុទសកៈឬសោតទសកៈ។

**ចំណាំ:** រូប២៨ ឥត្ថីភាវរូបមិនមានក្នុងបុរស ឯបុរិសភាវរូបមិនមានក្នុងស្ត្រី រូបមានត្រឹម ២៧ ប៉ុណ្ណោះ រមែងប្រាកដក្នុងខ្លួនសត្វបុគ្គលម្នាក់។

(ចប់ រូបន័យទី៤ រូបកលាប)

VIDEO 26

## រូបន័យទី ៥ រូបបវត្តិក្កម

(រូបប្រព្រឹត្តិទៅក្នុងបុគ្គលម្នាក់ៗ)

រូប ២៨ រមែងកើតក្នុងភូមិទាំងឡាយ តាមសមគួរក្នុងបវត្តិកាល រមែងមិនខ្វះខាត តែថា ក្នុងបដិសន្ធិកាលពោល ដោយ**ឧក្កដ្ឋន័យ** (ន័យដែលមិនខ្វះ

ខាត) រូបធម៌ទាំងឡាយរមែងកើតបានគ្រប់ តាមដែលពោលមក តែកាលពោលដោយ **ឱមកជ្ជន័យ** (ន័យដែលខ្វះខាត) រូបធម៌ រមែងខ្វះទៅតាមភូមិនិងឋាននោះៗ។

ការបន្តនៃរូបកលាបរបស់សត្វ ដែលមានកម្មជាសមុដ្ឋានចាប់តាំងពីបដិសន្ធិកាល។ ដែលមានចិត្តជាសមុដ្ឋានចាប់តាំងពីចិត្តទី២ គឺ ឧប្បាទក្ខណៈរបស់បឋមភវង្គចិត្ត។ ដែលមានឧតុជាសមុដ្ឋានចាប់តាំងពីឋិតិខណៈរបស់បដិសន្ធិចិត្ត និងអាហារជាសមុដ្ឋាន ចាប់តាំងពីឱជាដែលផ្សាយជ្រួតជ្រាបចូលទៅក្នុងសរីរៈ។

សមុដ្ឋានទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងភូមិដែលប្រព្រឹត្តទៅបានដោយមិនដាច់ខ្សែ រហូតដល់អាយុក្ខ័យ ដូចអណ្តាតភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ និងដូចក្រសែទឹក ដែលកំពុងជន់។

តែក្នុងមរណកាល សមុដ្ឋានទាំងឡាយ ដូចភ្លើងដែលកំពុងរលត់ ព្រោះកម្មជ្ជកលាប មិនកើតឡើងផ្តើមតាំងពីឋិតិខណៈរបស់ចិត្តទី ១៧ ដូចចុតិ ចំណែកកម្មជ្ជរូបដែលកើតមុននោះ រមែងប្រព្រឹត្តទៅរហូតដល់ចុតិចិត្តនោះឯង ហើយរលត់ទៅព្រមជាមួយចុតិចិត្ត តពីនោះ ចិត្តជ្ជរូប ក៏ប្រព្រឹត្តទៅរហូតអស់អាយុហើយរលត់ទៅ បន្ទាប់មក អាហារជ្ជរូប ក៏

ប្រព្រឹត្តទៅរហូតអស់អាយុ កាលអាហារអស់ក្នុងភពនេះ ការបន្តនៃរូបមានតែឧតុជរូបប៉ុណ្ណោះ ហើយប្រព្រឹត្តិទៅរហូតដល់សាកសពដែលត្រូវបោះចោល ទុកដូចកំណាត់ឈើគ្មានប្រយោជន៍ ដូចព្រះធម្មសេនាបតីសារីបុត្តពោលថា៖

**អាយុ ឧស្មា ច វិញ្ញាណំ**

**យទា កាយំ ជហន្តិមំ**

**អបវិទ្ធោ តទា សេតិ**

**និរត្ថំវ កលិង្គរំ។**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែង

លះបង់នូវកាយនេះ ទៅក្នុងកាលណាហើយ

(កាយនេះក៏ដល់នូវសេចក្ដីមិនគួរនឹងទុកដាក់

ឱ្យនៅលើផ្ទះសម្បែងបានឡើយ)គេតែង

នាំយកទៅចោលឱ្យដេកនៅលើផែនដី

ក្នុងកាលណោះឯង ដូចអង្កត់ឧស

រកប្រយោជន៍គ្មានឡើយ។

VIDEO 27

# សម្ដែងរូបដោយអាការ ៣

១.សម្ដែងរូបដោយភូមិ ២៧

២.សម្ដែងរូបដោយកាល ៣

៣.សម្ដែងរូបដោយកំណើត ៤

# រូបកើតក្នុងភូមិ ២៧

១.<u>**កាមភូមិ ១១**</u> គឺ អបាយភូមិ ៤ និងសុគតិភូមិ៧ កាលពោលដោយឧក្កដ្ឋន័យ (ន័យដោយឧក្រិដ្ឋ)

មានរូបកើតបាន ២៧ (វៀរភាវរូប) ដោយឱមកន័យ ក៏មានរូបណាមួយខ្វះខាត តាំងពីបដិសន្ធិកាល។

២.**<u>រូបភូមិ ១៥</u>** បឋមជ្ឈានភូមិ ៣ ទុតិយជ្ឈានភូមិ៣ តតិយជ្ឈានភូមិ ៣ ចតុត្ថជ្ឈានភូមិ ៦ (វៀរអសញ្ញ-សត្តភូមិ) មានរូបកើតបាន ២៣ រូបដោយវៀររូបទាំង ៥នេះ គឺ

១.ឃានបសាទរូប ២.ជិវ្ហាបសាទរូប ៣.កាយបសាទរូប ៤.ឥត្ថីភាវរូប ៥.បុរិសភាវរូប។ រូបទាំង ៥ នេះច្រើនប្រព្រឹត្តទៅក្នុងការឧបត្ថម្ភជួយកាមគុណា-រម្មណ៍ និងជាឧបនិស្ស័យរបស់កាមរាគៈយ៉ាងខ្លាំង

ក្លា ទើបមិនកើតក្នុងរូបព្រហ្មភូមិ ចំណែកចក្ខុបសាទរូប និងសោតបសាទរូបទាំង ២នេះ មានប្រយោជន៍ដល់ព្រហ្មបុគ្គលជាចំណែកច្រើន គឺក្នុងគ្រាខ្លះរមែងឱ្យបានទស្សនានុត្តរិយ និងសវនានុត្តរិយជាដើម និងសម្រេចមគ្គ ផល និព្វាន។

រូប ២៣ ដែលកើតដល់ព្រហ្មបុគ្គលនោះ ជារូបដែលមានប្រសិទ្ធភាពល្អ មិនមានការខ្វះខាត ដោយមានការឃើញ បានឆ្ងាយ និងឃើញបានច្បាស់ជាដើម។

៣.**<u>អសញ្ញសត្តភូមិ</u>** មានរូបកើតបាន ១៧ រូប បានដល់ អវិនិព្ភោគរូប ៨ មានជីវិតរូប១ បរិច្ឆេទរូប១ វិការរូប ៣ និងលក្ខណរូប ៤។

៤.**<u>អរូបភូមិ ៤</u>** ជាភូមិរបស់អរូបព្រហ្មបុគ្គល មានរូបណាៗ កើតឡើងទេ ដោយអំណាចនៃរូបវិរាគភាវនា ព្រោះមិនត្រេកអរ មិនប្រាថ្នា ក្នុងរូបធម៌ទាំងពួង ដូច្នេះ ពួកអរូបព្រហ្មបុគ្គល ទើបមិនមានរូប។

## កាមភូមិ ១១ ដោយសមុដ្ឋាន ៤

រូប ២៨ ដែលកើតក្នុងកាមភូមិ ១១ កាលចែកដោយសមុដ្ឋាន ៤ គឺ

| | |
|---|---|
| កម្មជរូប ១៨ | សរុបមាន ៥៨ រូប |
| ចិត្តជរូប ១៥ | |
| ឧតុជរូប ១៣ | |
| អាហារជរូប ១២ | |

# ចែកសមុដ្ឋានិករូបពិស្តារ

| | |
|---|---|
| ១.កម្មជ្ជរូប ១៨ និប្ផន្នរូប១៧ (វៀរបរិច្ឆេទរូប១) | លក្ខណរូប ៤X១៧ = ៦៨<br>កម្មជ្ជរូប ១៨ |
| សរុប | ៨៦ |

# ចិត្តជរូប ១៥

| | |
|---|---|
| ២.ចិត្តជ្ជរូប ១៥ និប្ផន្នរូប៩ (វៀររូប៦) | លក្ខណរូប ៤X៩ = ៣៦<br>ចិត្តជ្ជរូប ១៥ |
| សរុប | ៥១ |

## ឧតុជរូប ១៣

| | |
|---|---|
| ៣.ឧតុជរូប ១៣ និប្ផន្នរូប៩ (វៀររូប៤) | លក្ខណរូប ៤X៩ = ៣៦<br>ឧតុជរូប ១៣ |
| សរុប | ៤៩ |

## អាហារជរូប ១២

| | |
|---|---|
| ៤.អាហារជរូប ១២ និប្ផន្នរូប៨ (វៀររូប៤) | លក្ខណរូប ៤X៩ = ៣៦<br>អាហារជរូប ១២ |
| សរុប | ៤៤ |

## ចែករូប ២៣ រូបភូមិ ១៥ ដោយសមុដ្ឋាន៣

កម្មជរូប ១៣ (កើតមិនបាន ៥ រូប) ចិត្តជរូប ១៥ ឧតុជរូប ១៣។ វៀរអាហារជរូប ១២ ព្រោះព្រហ្មបុគ្គល មិនបរិភោគអាហារ។ កាលចែកដោយសមុដ្ឋាន ៣ រួមបាន ៤១ រូប កាលរួមជាមួយលក្ខណរូបមាន ១២ (៣X៤) ទើបត្រូវជារូប ៥៣ តែបើរាប់ធម្មតា ២៣ ប៉ុណ្ណោះ។

## ចែករូប ១៧ កើតក្នុងអសញ្ញសត្តភូមិ ដោយសមុដ្ឋាន ២ កាលចែកសមុដ្ឋានបាន ២គឺ

មានកម្មជាសមុដ្ឋាន និងឧតុសមុដ្ឋាន ពួកអសញ្ញសត្តព្រហ្ម មិនមានចិត្ត មិនមានបរិភោគអាហារ ទើបមិនមានចិត្ត និងអាហារជាសមុដ្ឋាន។

## សមុដ្ឋានរូប ២ មានរូបយ៉ាងនេះ

- **កម្មជរូបមាន** ១០ រូបគឺ អវិនិព្ភោគរូប ៨ បរិច្ឆេទរូប១ ជីវិតរូប ១
- **ឧតុជរូប** ១២ គឺអវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ វិការរូប ៣ (វៀរសទ្ទរូប)

សរុបមាន ២២ រូប កាលរួមលក្ខណរូប ៨ (២x ៤) ក៏ជារូប ៣០ រូបធម្មតាមាន ១៧។

## ២.តាមន័យនៃកាលមាន ៣ កាល

**១.បដិសន្ធិកាល** វេលាដែលនាមរូបកើតឡើងគ្រាដំបូងក្នុងភពថ្មី គឺឧប្បាទខណៈនៃបដិសន្ធិចិត្ត។

**២.បវត្តិកាល** វេលាដែលនាមរូបកើតរលត់ប្រព្រឹត្តទៅក្នុងភពជាតិនោះៗ គឺតាំងពីឋិតិខណៈនៃបដិសន្ធិចិត្តជាដើមមក រហូតដល់ឋិតិខណៈនៃចុតិចិត្ត។

**៣.ចុតិកាល** វេលានាមរូប ឃ្លាតចាកភពជាតិនោះៗ ភវង្គខណៈនៃចុតិចិត្ត។

## អធិប្បាយ

**១.បដិសន្ធិកាល** (គព្ភសេយ្យកសត្វ) មានរូប ៨ កើតមិនបាន គឺ សទ្ទរូប១ វិការរូប ៥ (វិញ្ញត្តិរូប ២ និងវិការ៣) ជរតារូប១ អនិច្ចតារូប១។

## ខណៈបដិសន្ធិកើតបាន ២០ គឺ

បសាទរូប ៥ ភាវរូប ២ ហទយរូប ១ ជីវិតរូប១ អវិនិព្ភោគរូប៨ បរិច្ឆេទរូប១ ឧបច្ចយរូប១ សន្តតិរូប ១ កើតពីកម្មជាសមុដ្ឋានតែម្យ៉ាង។

**២.បវត្តិកាល** រូបទាំងអស់ ២៨ រមែងកើតបាន តាមសមគួរដល់ភូមិ និងកំណើតរបស់សត្វនោះៗ កើតបានទាំង ៤ សមុដ្ឋាន។

**៣.ចុតិកាល** ក្នុងវេលាដែលសត្វស្លាប់រូបកើតមិនបានគឺ

- **កម្មជរូប** ទាំងអស់នៃសត្វទាំងពួង
- **ចិត្តជរូប** ចំពោះរបស់ព្រះអរហន្ត

## រូបដែលកើតក្នុងចុតិកាល

**ក.ចិត្តជរូប** ដែលកើតក្នុងឧប្បាទខណៈនៃចុតិរបស់សត្វក្នុងបញ្ចវោការភព (វៀរចុតិរបស់ព្រះអរហន្ត)។

**ខ.អាហារជរូប** ជារូបអាចកើតបានគ្រប់ៗ អនុខណៈនៃចិត្ត ក្នុងភង្គខណៈនៃចុតិចិត្ត អាហារជរូប នៅកើតបានគ្រាចុងក្រោយ។

**គ.ឧតុជរូប** ជាឧតុជរូបកើតបានពីសមុដ្ឋានទាំង ៤ បានដល់

**១.កម្មប្បច្ចយឧតុជរូប** ឧតុជរូបដែលមានកម្មជាបច្ច័យ

**២.ចិត្តប្បច្ចយឧតុជរូប** ឧតុជរូបដែលមានចិត្តជាបច្ច័យ

**៣.ឧតុប្បច្ចយឧតុជរូប** ឧតុជរូបដែលមានឧតុជាបច្ច័យ

**៤.អាហារប្បច្ចយឧតុជរូប** ឧតុជរូបដែលមានអាហារជាបច្ច័យ។

ដល់កាលណា **តិជរូប** គឺរូបដែលកើតពីកម្ម ចិត្ត អាហារ រលត់អស់ហើយ យ៉ាងនេះក៏កើតបន្តគ្នានៃឧតុជរូបមានរោម សក់ជាដើម តាំងនៅរហូតដល់សាកសពវិនាសបាត់។

## ៣.សម្ដែងរូប ២៨ ដោយកំណើត ៤

### កំណើត ៣ ឬ ៤

**១.សំសេទជ:** កំណើតកើតក្នុងញើស ក្អែល ឬក្នុងទីអាប់អួរ ស្មោកគ្រោក។ សត្វទាំងឡាយ ដែលបដិសន្ធិដោយមិនអាស្រ័យមាតា គឺអាស្រ័យដើមឈើ ផ្កាឈើខ្លះ ផ្លែឈើខ្លះ លោហិតជាដើម ដូចចិញ្ចាមាណវិកា កើតពីដើមអំពិល នាងវេឡុវតី កើតពីដើមឫស្សី នាងបទុមវតី កើតពីផ្កាឈូក ឱរសនាងបទុមវតី៥០០នាក់, ៤៩៩ នាក់ កើតពីញើស ម្នាក់កើតក្នុងគភ៌។

**២.ឱបបាតិកៈ** កំណើតកើតផុសឡើង ចម្រើនពេញទី (ធំពេញរូបរាងភ្លាម) ។ កំណើត អាស្រ័យ

អតីតកម្មតែម្យ៉ាង ដូចហោះមកពីភពដទៃ ឬដូចធ្លាក់អំពីទីខ្ពស់បានដល់៖

- មនុស្សសម័យដើមកប្ប
- ទេវតាទាំង ៦ ជាន់ (វៀរទេវតាជាន់ទាបខ្លះ)
- ព្រហ្មទាំងអស់
- ប្រេត រួមទាំងនិជ្ឈាមតណ្ហិកប្រេត
- អសុរកាយ និងសត្វនរកទាំងអស់។

**៣.គព្ភសេយ្យកៈ** កំណើតកើតក្នុងគភ៌មាតា ចែកចេញជា ២ គឺ

- **អណ្ឌជៈ** កំណើតកើតអំពីស៊ុត សត្វប្រភេទនេះ ហៅថា ទ្វិជៈកំណើត (កើត២ ដង) ដូចជាមាន់ ទា ចាប ក្អែក ជីងចក់ តុកកែ ពស់ ជាដើម។ ម្យ៉ាងទៀត មានក្នុងសត្វតិរច្ឆានខ្លះ ប្រេតខ្លះ អសុរកាយខ្លះ ទេវតាជាន់ទាបខ្លះ មនុស្សខ្លះក៏មាន។
- **ជលាពុជៈ** កំណើតកើតក្នុងស្បូន គឺកើតពីម្តាយ កើតជាទារកកូនង៉ែតសិន ចម្រើនធំឡើងសន្សឹមៗ តាមលំដាប់បានដល់ មនុស្ស សត្វ ទេវតាជាន់ទាប ប្រេត (និជ្ឈាមតណ្ហិកប្រេត)។

# ចែកកំណើត ៤ ដោយកម្មជរូបកលាប ៩

# ក្នុងកាមភូមិ ១១ និងរូបភូមិ ១៦

| សំសេទជ និងឱបបាតិក (បដិសន្ធិ) | |
|---|---|
| **ឧក្កដ្ឋន័យ ៧** | **ឱមកន័យ ៤** |
| ១.ចក្ខុទសក<br>២.សោតទសក<br>៣.ឃានទសក<br>៤.ជិវ្ហាទសក<br>៥.កាយទសក<br>៦.ហទយទសក<br>៧.ភាវទសក | **១.សំសេទជ** មាន ៤ គឺ ចក្ខុ.សោត.ឃាន.ភាវ.<br>**២.ទុគ្គតិឱបបាតិក** មាន ៣គឺ ចក្ខុ.សោត. ភាវ.<br>**៣.សុគតិឱបបាតិក** មនុស្សដើមកប្បមានភាវខ្វះខាត<br>**៤.ពួកឱបបាតិក** មាន កម្មជកលាបកើតបាន៧ គ្រប់បរិបូណ៌ |

## ឱបបាតិកកំណើតជារូបព្រហ្ម(ទៀរអសញ្ញី)

| ឱបបាតិកកំណើត | |
|---|---|
| **បដិសន្ធិកាល** | **បវត្តិកាល** |
| **មានកម្មជកលាប ៤ គឺ**<br>១.ចក្ខុទសក<br>២.សោតទសក<br>៣.ឃានទសក<br>៤.ជិវ្ហាទសក | មិនមានកលាបកើត ឡើងថែមទៀតទេ។ |

**៣.ពួកឱបបាតិកកំណើត** ដែលជាអសញ្ញសត្តាព្រហ្មទាំងបដិសន្ធិកាល ទាំងបវត្តិកាល មានជីវិតនវកកលាប១ប៉ុណ្ណោះ។

**៤.គព្ភសេយ្យកកំណើត** ក្នុងបដិសន្ធិកាលដោយឧក្កដ្ឋន័យ មានកម្មជកលាបកើតបាន ៣ គឺ កាយទសកកលាប

១ ភាវទសកកលាប១ វត្ថុទសកកលាប១។ ដោយឱមកន័យខ្វះខាតមាន ២ គឺ កាយទសកកលាប១ និងវត្ថុទសកកលាប១។

ក្នុងបវត្តិកាល កម្មជកលាប រមែងកើតបានទៀត ៥ គឺ ចក្ខុទសកកលាប១ សោតទសកកលាប១ ឃានទសកកលាប១ ជិវ្ហាទសកកលាប១ ជីវិតនវកកលាប។

## សម្តែងការចម្រើននៃរូបតាំងពីបដិសន្ធិរហូតដល់គ្រប់របស់គព្ភសេយ្យកកំណើត

សប្តាហ៍ទី១ **កលលរូប** មានលក្ខណដូចទឹកថ្លា ដូចដំណក់ប្រេងល្ង។

សប្តាហ៍ទី២ **អព្វុទរូប** មានលក្ខណៈដូចជាពពុះខន់ពណ៌ដូចទឹកលាងសាច់។

សប្តាហ៍ទី៣ **បេសិរូប** មានលក្ខណៈជាដុំសាច់រាវៗពណ៌ក្រហម។

សប្តាហ៍ទី៤ **ឃនរូប** មានលក្ខណៈជាដុំ មានសណ្ឋានដូចពងមាន់។

សប្តាហ៍ទី៥ កើតជា **បញ្ចសាខា** គឺរូបនេះបែងចែកជាពក ៥ គឺ ដៃ ២ ជើង ២ ក្បាល១។

**តតោ បរំ** បន្តពីនោះមក ក្នុងរវាងសប្តាហ៍ទី ១២ ដល់សប្តាហ៍ទី ៤២ មានសក់ រោម ក្រចក ទាំងនេះប្រាកដ។

## សម្តែងការកើតឡើងរបស់ចិត្តជរូប ឧតុជរូប និងអាហារជរូប

សត្វក្នុងបញ្ចវោការភព បដិសន្ធិចិត្តកើតព្រមនឹងកម្មជរូប ក្នុងបដិសន្ធិកាល។ លុះបដិសន្ធិចិត្តរលត់ទៅចិត្តដួងទី២ ដែលកើតបន្ត បានដល់ បឋមភវង្គចិត្តជរូប ក៏ផ្តើមឡើងដំបូងត្រង់ឧប្បាទខណៈនៃចិត្ត

ចំណែកឋិតិខណៈ និងភង្គខណៈរបស់ចិត្ត ចិត្តជរូប មិនកើតបានឡើយ។

**ឧតុជរូប** ចាប់ផ្តើមឡើងជាដំបូងត្រង់ឋិតិខណៈនៃបដិសន្ធិចិត្ត និងរមែងកើតគ្រប់ៗខណៈនៃចិត្ត ព្រោះឧតុជរូបកើតអាស្រ័យឧតុជាសមុដ្ឋាន មិនកើតពីចិត្តនិងចេតសិកទេ។

អាហារជរូប ចំពោះសំសេទជៈនិងឱបបាតិកនោះ កាលបដិសន្ធិហើយ តពីនោះ ក៏បរិភោគអាហារបានភ្លាម។ អាហារជរូបនៃបុគ្គល២ ពួកនេះ ផ្តើមកើតជាដំបូងត្រង់មនោទ្វារវិថី កើតក្រោយពីបដិសន្ធិចិត្តនិងភវង្គកើតត្រង់គ្រប់ៗខណៈនៃចិត្ត។ ចំណែកអាហារជរូបដែលកើតក្នុងគព្ភសេយ្យកសត្វ កើតនៅពេលអាហារផ្សេងៗ ដែលមាតាបរិភោគ

ចូលទៅនោះ ជ្រួតជ្រាបផ្សាយទៅក្នុងរាងកាយរបស់សត្វដែលនៅក្នុងគភ៌របស់មាតា។ ភាវៈនៃឧតុ និងឱជា មានកម្លាំងក្នុងឋិតិខណៈប៉ុណ្ណោះនៃខ្លួនប៉ុណ្ណោះ[៧]។

**យញ្ចស្ស ភុញ្ជតិ មាតា**
**អន្នំ បានំ បានញ្ច**
**តេជនំតេន សោ តត្ថ**
**យាបេតិ មាតុកុច្ឆិគ្គតោ នរោ។**

ឯមាតារបស់ទារកនោះ បរិភោគអាហារណា
ជាបាយក្តី គ្រឿងផឹកក្តី ទារកដែលកើតក្នុង
គភ៌មាតា ជាគ្រឿងដណ្តប់នៅនោះ សត្វដែល
នៅក្នុងផ្ទៃនៃមាតានោះ ក៏ញ៉ាំងអត្តភាពឱ្យ

[៧] អភិធម្មត្ថវិភាវនីដីកា

ប្រព្រឹត្តទៅបានដោយភោជននោះ ដូច្នេះ[៩]។

Video 29

## និព្វានបរមត្ថ

ព្រះនិព្វានជាបរមត្ថធម៌ដែលល្អិត ប្រណីតជាងធម៌ណាៗ ទាំងអស់ ជាធម៌ជ្រាលជ្រៅ ឃើញបានលំបាក ដឹងបានលំបាក ស្ងប់ប្រណីត គិតស្មានមិនបានទេ ដឹងបានចំពោះតែបណ្ឌិតដែលបានសម្រេចមគ្គហើយ និងគប្បីដឹងច្បាស់ដោយខ្លួនឯង ជាអារម្មណ៍របស់មគ្គផល។

[៩] សំយុ.សគា. ឥន្ទកសូត្រ ៣០.២៨២/២០៨

**និព្វានំ បន លោកុត្តរសង្ខាតំ ចតុមគ្គញ្ញាណេន សច្ឆិកាតព្វំ មគ្គផលានមារម្មណភូតំ វានសង្ខាតាយ តណ្ហាយ និក្ខន្តត្តា និព្វានន្តិ បវុច្ចតិ។** ប្រែថា ចំណែកនិព្វានដែលព្រះមានព្រះភាគ ត្រាស់ថា ជាលោកុត្តរ ដែលព្រះអរិយៈ គប្បីធ្វើឱ្យជាក់ច្បាស់ដោយមគ្គញ្ញាណទាំង ៤ ជាអារម្មណ៍របស់មគ្គនិងផល ហៅថា និព្វាន ព្រោះតណ្ហាដែលហៅថា **វាន**។

## វចនត្ថៈនិព្វាន

**និ** មិនមាន **ឬ និក្ខន្តំ** ចេញហើយ

**វាន** ប្រែថា គ្រឿងរួមរឹត **និវាន** (**និព្វាន**) មិនមានគ្រឿងរួមរឹត។

## និព្វានមានតេជានុភាពច្រើន

## ឧបមាដូចជា៖

មានព្រះរាជាមួយអង្គ មានតេជានុភាពច្រើន ហើយមានមេស្រុកម្នាក់ ក្នុងស្រុកដ៏ធំមួយក្នុងដែនដីរបស់ព្រះអង្គ និងមានមេស្រុកម្នាក់មានបរិវារច្រើន។ មេស្រុកនិងចោរក៏ព្យាយាមប្រហារគ្នា ក្រោយមកមេស្រុក បានចូលទៅកាន់ព្រះនគរប្រតិបត្តិព្រះរាជា មិនយូរប៉ុន្មានមេស្រុកនេះ ក៏ក្លាយជាស្និទ្ធស្នាលនឹងព្រះរាជា បានទទួលអំណាចដ៏ធំពី

ព្រះរាជា មេចោរបានឮដំណឹងនេះហើយក៏ត្រិះរិះថា បើយើងនៅទីនេះតទៅទៀត មុខជាមិនមានជីវិតរស់នៅទៅទៀតបានពិតប្រាកដ។ ទើបគេចូលទៅព្រៃជាមួយនឹងបរិវាររបស់ខ្លួន។ ចំណែកមេស្រុកមិនបណ្ដោយឱ្យពួកចោរគេចផុតបានឡើយ កាលចាប់ពួកចោរនោះបានហើយ ក៏ប្រហារជីវិតតែម្ដង សេចក្ដីនេះមានឧបមេយ្យដូច្នោះ។

- ❖ ព្រះនិព្វានឧបមាដូចព្រះរាជាមានតេជានុភាពច្រើន
- ❖ ញាណដូចមេស្រុក
- ❖ មោហៈដូចមេចោរ
- ❖ កិលេសដ៏សេសដូចជាបរិវារចោរ

- ❖ ញាណរបស់បុថុជ្ជន ដូចមេស្រុកក្នុងពេលមិនទាន់ចូលប្រតិបត្តិព្រះរាជា
- ❖ មគ្គញ្ញាណដូចមេស្រុក បានចូលទៅប្រតិបត្តិព្រះជារាហើយ។

ព្រះនិព្វានមិនអាចពោលថា មិនមានក្នុងកាលឯណោះ ឬទិសឯណោះ ក្នុងទិសទាំងអស់ និងក្នុងសង្សារវដ្ត ដែលមិនមានអ្នកដឹងខាងដើមបាន និងខាងចុង ព្រោះជាធម៌ដែលគេអាចពោលដូច (ចិត្ត) មិនបាន។ **សួរថា** ព្រោះហេតុដូចម្ដេច?

**ឆ្លើយថា:** ព្រោះនិព្វានមានគ្រប់ទីកន្លែង ដោយភាពជាធម៌ដែលបន្លុះ បានពិតក្នុងកាលណាមួយ ឬទីណាមួយមានសម្ដែងក្នុងអង្គុត្តរនិកាយថា៖

**សេយ្យថាបិ ភិក្ខវេ យា កាចិ លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ ឯវមេវ ខោ ភិក្ខវេ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ** ម្នាលភិក្ខុទាំងឡាយ ទន្លេឯណា នៅក្នុងលោករមែងហូរទៅកាន់មហាសមុទ្រ ធារទឹករមែងធ្លាក់ចុះអំពីអាកាស ទៅកាន់មហាសមុទ្រមិនប្រាកដថា ខ្វះឬពេញ ដោយហេតុនោះ យ៉ាងណាមិញ សូម្បីភិក្ខុចំនួនច្រើនបរិនិព្វានដោយការរំលត់

មិនមានខន្ធសេសសល់និព្វានធាតុ ក៏មិនប្រាកដភាពខ្វះឬ ពេញយ៉ាងនោះដែរ។

**អដ្ឋកថា:** ពាក្យថា និព្វានធាតុក៏មិនប្រាកដភាពខ្វះឬពេញ) មានសេចក្តីថា នាកាលព្រះពុទ្ធទាំងឡាយទ្រង់មិនឧបត្តិឡើង ក្នុងមហាកប្បរាប់មិនបាន សូម្បីបុគ្គលម្នាក់ក៏មិនអាចបរិនិព្វាន កាលនោះ រមែងពោលមិនបានថា និព្វានធាតុទទេ ចំណែកក្នុងសម័យពុទ្ធកាល សូម្បីសត្វលុះក្នុងអមតធម៌ ក្នុងពេលស្តាប់ធម៌ម្តងៗ រាប់មិនបាន ក្នុងកាលនោះក៏ពោលថា និព្វានធាតុពេញមិនបាន។

**ព្រហ្មនិមន្តនសូត្រពោលថា៖**

**វិញ្ញាណំ អនិទស្សនំ អនន្តំ សព្វតោបភំ។**
និព្វានដែលគប្បីដឹងច្បាស់ពោល (ថាមានសណ្ឋាន ដូចនេះ) មិនបាន មិនមានព្រំដែន ផូរផង់ក្រៃលែង។

**តើអ្វីជានិព្វាន?**

**អាភិញ្ញានំ អនាទានំ ឯតំ ទីបំ អនាបរំ**

**និព្វានំ ឥតិនំ ព្រូមិ ជរាមច្ចុបរិក្ខយំ៕**

ការមិនកង្វល់ ការមិនប្រកាន់មាំ នុ៎ះឯង

ជាទីពឹង ឯទីពឹងក្រៅនេះ ពុំមានទេ

តថាគតហៅនូវទីពឹងនោះថានិព្វាន ជាទីអស់

ទៅនៃជរានិងមច្ចុដោយប្រការដូច្នេះ។

## លក្ខណៈរបស់ព្រះនិព្វាន

១.ការមិនកើតឡើងរបស់នាមរូប ជានិព្វាន

២.ការមិនប្រព្រឹត្តទៅរបស់នាមរូប ជានិព្វាន

៣.ការមិនមានសង្ខារនិមិត្តគឺនាមរូប ជានិព្វាន

៤.មិនមានសេចក្តីខ្វល់ខ្វាយ (កុសលនិងអកុសល) ជានិព្វាន

៥.ការមិនមានកើតសង្ខារថ្មីជានិព្វាន (វិបស្សនាភាគ៣)

## សព្ទសម្ដែងដល់ព្រះនិព្វាន

✓ **និព្វន្តិ ធីរា** អ្នកមានបញ្ញារមែងរលត់
✓ **និព្វាបេន្តិ រាគគ្គិំ** ញ៉ាំងភ្លើងរាគៈឱ្យរលត់
✓ **បរិនិព្វាយតិ** រមែងបរិនិព្វាន
✓ **បរិនិព្វាតុ សុគតោ** សូមព្រះសុគតមេត្តាបរិនិព្វាន

✓ **បរិនិព្វាបេយ្យ** គប្បីបរិនិព្វាន
✓ **បរិនិព្វាយិស្សតិ** នឹងបរិនិព្វាន
✓ **អន្តរាបរិនិព្វាយី** អ្នកបរិនិព្វានក្នុងចន្លោះ
✓ **បរិនិព្វុតោ** បរិនិព្វានហើយ។

## រូបវិគ្រោះព្រះនិព្វាន

**និព្វាតិ វដ្តទុក្ខំ ឯត្ថាតិ និព្វានំ** ទុក្ខក្នុងវដ្តៈ រមែងរលត់ទៅក្នុងសភាវៈនេះ ហេតុនោះសភាវៈនោះ ឈ្មោះថា និព្វាន។

**និព្វាតិ វដ្តទុក្ខំ ឯតស្មឹ អធិគតេតិ និព្វានំ** ទុក្ខក្នុងវដ្តៈ រមែងរលត់កាលបុគ្គលសម្រេចសភាវៈនេះ ហេតុនោះសភាវៈនោះ ឈ្មោះថា និព្វាន។

## និព្វានជាសភាវរលត់

**ទុទ្ទសោ** ឃើញបានដោយលំបាក

**បណ្ឌិតវេទនីយោ** ជាវិស័យដែលបណ្ឌិតនឹងគប្បីដឹងច្បាស់។

**អប្បដិភាគំ មហារាជ និព្វានំ។ ន សក្កា និព្វានស្ស រូបំ វា សណ្ឋានំ វា វយំ វា ឱបម្មេន វា ការណេន វា ហេតុនា វា នយេន វា ឧបទស្សយិតុំ។** បពិត្រមហារាជនិព្វាន មិនមានវត្ថុណា ប្រៀបបានបុគ្គលមិនអាចសម្តែងពណ៌ រូបរាង ខ្នាត ឬចំនួនរបស់ព្រះនិព្វាន ដោយការប្រៀបធៀប ដោយហេតុជួយ ដោយហេតុគោល ឬដោយន័យ (ដែលអនុមានដឹង) (មលិន្ទបញ្ហា)

## លក្ខណាទិតិករបស់និព្វាន

១.មានសេចក្តីស្ងប់ចាកកិលេសនិងខន្ធជាលក្ខណៈ

២.មានសេចក្តីមិនកម្រើកញ៉រ ជារស ឬសភាពស្រាលចិត្ត ជារស

៣.មិនមាននិមិត្ត ឬ មានការចេញទៅជាអាការប្រាកដ

ព្រះនិព្វានមិនមានហេតុជិតឱ្យកើត។

## គុណរបស់និព្វាន ៥

១.**បទំ** ប្រែថា ធម៌មួយចំណែក

២.**អច្ចុតំ** ប្រែថា មិនកម្រើកញ៉រ

៣.**អច្ចន្តំ** ប្រែថា ឈានកន្លង

៤.**អសង្ខតំ** ប្រែថា មិនមានបច្ច័យប្រជុំតាក់តែង

៥.**អនុត្តរំ** ប្រែថា ធម៌ដែលប្រសើរបំផុត

**អមតំ អសង្ខតំ បរមំ សុខំ** អមតនិព្វានមិនមានអ្វីប្រជុំតាក់តែង ជាសុខក្រៃលែង។

**និព្វានមាន ១ គឺ** សន្តិលក្ខណៈ មានការស្ងប់ ជាលក្ខណៈ

**និព្វានមាន ២ គឺ** សឧបាទិសេសនិព្វាន១ អនុបាទិសេសនិព្វាន ១។

## ព្រះនិព្វានមាន ៣

១.**សុញ្ញតនិព្វាន** ព្រោះសូន្យចាកសង្ខារទាំងពួង

២.**អនិមិត្តនិព្វាន** ព្រោះមិនមាននិមិត្តគឺ សង្ខារទាំងពួង

៣.**អប្បណិហិតនិព្វាន** ព្រោះមិនមានទីតាំងគឺសង្ខារទាំងពួង។

## ឈ្មោះព្រះនិព្វាន ១៤៣ បទ

១.**មោក្ខោ** សភាវៈជាទីផុតចាកកិលេសមានរាគៈជាដើម

**២.និរោធោ** សភាវៈជាទីរលត់កិលេសមានរាគៈជាដើម

**៣.និព្វានំ** សភាវៈជាទីផុតចាកតណ្ហា

**៤.ទីបោ** សភាវៈជាទីតាំងមាំដូចជាកោះ

**៥.តណ្ហក្ខយោ** សភាវៈជាហេតុអស់ទៅនៃតណ្ហា

**៦.បរំ** សភាវៈជាទីបដិបក្ខចំពោះរាគៈជាដើម

**៧.តាណំ** សភាវៈជាទីជ្រកកោន

**៨.លេណំ** សភាវៈជាទីពួន

**៩.អរូបំ** សភាវៈដែលមិនមានរូប

១០.**សន្តំ** សភាវៈដែលស្ងប់រាគៈជាដើម

១១.**សច្ចំ** សភាវៈដែលជាប់ក្នុងសច្ចៈ

១២.**អនាលយំ** ដែលមិនមានអាល័យគឺតណ្ហា

១៣.**អសង្ខតំ** មិនត្រូវបច្ច័យតាក់តែង

១៤.**សិវំ** សភាវៈដែលធ្វើឱ្យសិរៈគឺក្សេម

១៥.**អមតំ** សភាវៈដែលមិនមានសេចក្ដីស្លាប់

១៦.**សុទុទ្ទសំ** សភាវៈដែលឃើញបានដោយលំបាក

១៧.**បរាយណំ** សភាវៈដែលព្រះអរិយគប្បីដល់

**១៨.សរណំ** សភាវៈដែលជាហេតុបៀតបៀនកិលេស

**១៩.អនីតិកំ** សភាវៈដែលមិនមានចង្រៃ

**២០.អនាសវំ** សភាវៈដែលមិនជាអារម្មណ៍របស់អាសវៈ

**២១.ធុវំ** សភាវៈដែលទៀងពិត

**២២.អនិទស្សនំ** សភាវៈដែលមិនឃើញបានដោយភ្នែក

**២៣.អកតំ** សភាវៈដែលមិនត្រូវបច្ច័យទាំង ឡាយប្រជុំតាក់តែង

**២៤.អបលោកិតំ** សភាវៈដែលមិនរលត់

**២៥.និបុណំ** សភាវៈល្អិតសុខុម

**២៦.អនន្តំ** សភាវៈដែលមិនមានសេចក្ដីវិនាស

**២៧.អក្ខរំ** សភាវៈដែលសាបសូន្យវិនាសទៅ

**២៨.ទុក្ខក្ខយោ** សភាវៈដែលជាហេតុអស់ទុក្ខទាំងពួង

**២៩.អព្យាពជ្ឈំ** សភាវៈដែលមិនមានសេចក្ដីវិនាស

**៣០.វិវដ្ដំ** សភាវៈដែលមិនមានវដ្ដ ៣

**៣១.ខេមំ** សភាវៈដែលមិនមានភ័យ

**៣២.គេហលំ** សភាវៈដែលមិនលាយឡំនិងមិនប្រកបដោយសង្ខារ

**៣៣.អប្បវត្តោ** សភាវៈដែលគេចចេញនៃសង្ខារ

**៣៤.វិរាគោ** សភាវៈដែលប្រាសចាករាគៈ

**៣៥.បណីតំ** សភាវៈដែលនាំទៅកាន់សេចក្ដីប្រសើរ

**៣៦.អច្ចុតំ** សភាវៈដែលព្រះអរិយបន្លុះហើយ

**៣៧.បទំ** សភាវៈដែលព្រះអរិយគប្បីបន្លុះ

**៣៨.យោគក្ខេមោ** សភាវៈដែលជាហេតុអស់នៃយោគៈ

**៣៩.ធារំ** សភាវៈដែលរម្ងាប់ការក្ដៅក្រហាយ

**៤០.មុត្តិ** សភាវៈដែលរួចផុតចាកកិលេស

**៤១.សន្តិ** សភាវៈដែលស្ងប់រម្ងាប់កិលេស

**៤២.វិសុទ្ធិ** សភាវៈដែលជាហេតុវិសេសចាកមន្ទិល

**៤៣.វិមុត្តិ** សភាវៈដែលរួចចាកសង្ខារ

**៤៤.អសង្ខតធាតុ** សភាវៈដែលមិនមែនសត្វ មិនមែនជីវៈ

**៤៥.សុទ្ធិ** សភាវៈដែលហ្មត់ចត់ចាកមន្ទិល

**៤៦.និព្វុតិ** សភាវៈដែលចាកតណ្ហាឈ្មោះថា វុតិ

**៤៧.សីតិភាវោ** សភាវៈដែលត្រជាក់ជាសុខ

**៤៨.វិសង្ខារោ** សភាវៈដែលចេញចាកសង្ខារ

**៤៩.អប្បមាណំ** សភាវៈដែលប្រមាណមិនបាន

**៥០.អកិញ្ចនំ** សភាវៈដែលមិនមានគ្រឿងកង្វល់គឺកិលេស

**៥១.រាគក្ខយោ** សភាវៈដែលអស់ទៅនៃរាគៈ

**៥២.អព្យាបជ្ឈោ** មិនមានសេចក្តីវិនាស

**៥៣.អប្បបញ្ចំ** សភាវៈដែលមិនមានកិលេសជាគ្រឿងយឺតយូរ

**៥៤.អជរំ** មិនចាស់ទ្រុឌទ្រោមដោយជរា

**៥៥.ទោសក្ខយោ** អស់ទៅនៃទោសៈ

**៥៦.អនុប្បាទោ** មិនមានការកើតឡើង

**៥៧.អប្បវត្តំ** មិនមានការប្រព្រឹត្តទៅនៃខន្ធ

**៥៨.អនង្គណំ** មិនមានកិលេសជាទីទួល

**៥៩.មោហក្ខយោ** អស់ទៅនៃមោហៈ

**៦០.អនិមិត្តំ** មិនមាននិមិត្តគឺខន្ធ ៥

**៦១.និប្បបញ្ចំ** ចេញចាកកិលេស

**៦២.អនុត្តរំ** មិនមានធម៌ដទៃក្រៃលែងជាង

**៦៣.និមោក្ខោ** ផុតចាកទុក្ខទាំងពួង

**៦៤.បដិនិស្សគ្គោ** លះតណ្ហា

**៦៥.បដិសនិស្សគ្គោ** សភាវៈដែលលះតណ្ហា

**៦៦.អតិទុល្លភោ** សភាវៈដែលបានដោយលំបាក

**៦៧.ចិមោក្ខោ** សភាវៈដែលរួចផុតចាកសង្ខារ

**៦៨.អនុបាយំ** មិនដែលមានសេចក្ដីចង្អៀតចង្អល់

**៦៩.អសាធារណំ** មិនទូទៅ

**៧០.អច្ចុតំ**ជាធម៌អស្ចារ្យកើតមានឡើងក្នុងញាណ

**៧១.អប្បដិសន្ធិ** មិនមានកំណើត

**៧២.ទុប្បស្សំ** ឃើញបានដោយលំបាក

**៧៣.អនុបទ្ទវំ** មិនមានធម៌ណាៗបៀតបៀន

**៧៤.ឧត្តរំ** ឆ្លងផុតលោកទាំងពួង

**៧៥.អតក្កាវចរោ** ផុតចាកការត្រិះរិះ

**៧៦.ចាគោ** លះបង់តណ្ហា

**៧៧.អជរាមរណំ** មិនមានសេចក្តីចាស់និងស្លាប់

**៧៨.សុខំ** ដែលមានសុខ

**៧៩.មទនិម្មទនោ** ស្វាងសេចក្តីស្រវឹង

**៨០.និច្ចំ** ទៀងពិតប្រាកដ

**៨១.បិបាសវិនយោ** កម្ចាត់សេចក្តីក្តៅក្រហាយក្នុងកាម

**៨២.ဝរំ** សភាវៈប្រសើរជាងធម៌ទាំងពួង

**៨៣.នាមំ** ញ៉ាំងចិត្តនិងចេតសិកឱ្យបង្អោនទៅ

**៨៤.អនុបសជ្ជត្តំ** សភាវៈដែលប្រមាណមិនបាន

**៨៥.អនុបបត្តិ** មិនមានការកើតថ្មី

**៨៦.អន្តោ** ដែលចូលដល់បាន (ភាវនាបញ្ញា)

**៨៧.អគតិ** មិនមានទីកើត

**៨៨.គម្ភីរំ** សភាវៈដែលជ្រៅ

**៨៩.បតិដ្ឋា** ជាទីតាំងមាំ មិនធ្លាក់ចុះក្នុងវដ្តសង្សារ

**៩០.អសមំ** មិនមានធម៌ស្មើដូច

**៩១.អជរំ** មិនមានចាស់ជរា

**៩២.អភាចំ** ជាធម៌មិនមានទោស

**៩៣.អរណំ** មិនមាន **រណ** កិលេសជាដែលហេតុឱ្យស្រែកយំ

**៩៤.ជេដ្ឋំ** ខ្ពស់បំផុតឬគួរសរសើរក្រៃលែង

**៩៥.សន្តិបទំ** ជាស្ថានស្ងប់រម្ងាប់

**៩៦.បរាយនំ** ដែលព្រះអរិយគប្បីដល់

**៩៧.អនុបសគ្គំ** មិនមានធម៌ណាមករារាំង

**៩៨.សេដ្ឋំ** សភាវៈដែលប្រសើរ

**៩៩.អព្យាធិ** មិនមានព្យាធិ

**១០០.សុញ្ញតោ** សភាវៈទទេចាកតួខ្លួន

**១០១.សព្វូបធិបដិនិស្សគ្គោ** លះឧបធិទាំងពួង

**១០២.និស្សរណំ** រត់ចេញចាកសង្សារ

**១០៣.អជាតំ** ដែលមិនមានការកើតឡើង

**១០៤.វិមលំ** ប្រាសចាកមន្ទិលមានរាគៈជាដើម

**១០៥.រាគវិរាគោ** ប្រាសចាកតម្រេក

**១០៦.វិវេកោ** ស្ងាត់ចាកទុកទាំងពួង

**១០៧.អនតំ** មិនបង្អោនទៅដោយតណ្ហា

**១០៨.ទុរនុពោធោ** ស្ងួម្បីសន្សំបុណ្យបន្តិចដោយលំបាក

**១០៩.អប្បណិហិតំ** មិនមានរាគបណិធិ

**១១០. អនាយូហនំ** មិនប្រមូលមក គឺសមុទយៈ

**១១១.អនុបសគ្គធម្មំ** ដែលធម៌ណាៗរារាំងមិនបាន

**១១២.អប្បដិសមំ** មិនមានធម៌ដទៃប្រៀបផ្ទឹម

**១១៣.អនីតិកធម្មំ** មិននាំមកនូវសេចក្ដីអន្តរាយ

**១១៤.អាលយសមុគ្ឃាតោ** លះសេចក្ដីអាល័យក្នុងកាមគុណ ៥ មិនមានសល់

**១១៥.អសេសនិរោធោ** ជាទីរលត់តណ្ហា

**១១៦.អសេសវិរាគោ** ជាទីទម្លាយរាគៈមិនមានសល់

**១១៧.សឧបាទិសេសំ** អស់កិលេសតែនៅសល់ខន្ធ

**១១៨.វដ្ដុបច្ឆេទោ** ជាទីកាត់វដ្ដៈ

**១១៩.អបរិទេវំ** មិនមានសេចក្ដីសោក

**១២០.អនុបាទិសេសំ** មិនមានខន្ធសល់នៅ

**១២១.បណ្ឌិតវេទនីយោ** បណ្ឌិតទើបបន្លុះបាន

**១២២.សព្វសង្ខារសមថោ** ទីស្ងប់សង្ខារទាំងពួង

**១២៣.អប្បវត្តំ** ព្រោះមិនមានចំណែកដែនកើត

**១២៤.វិសោកំ** មិនមានហេតុនៃសោក

**១២៥.អសោកំ** មិនមានសោក

**១២៦.អភូតំ** មិនមានការកើតឡើង

**១២៧.អច្ឆរិយំ** ជាធម៌ដែលគួរឱ្យសរសើរ

**១២៨.ឧបសមោ** ចូលទៅស្ងប់

**១២៩.លោកុត្តរំ** ជាធម៌ក្រៃលែងជាងលោក

**១៣០.អទស្សនំ** ឃើញមិនបានដោយភ្នែក

**១៣១.វិរជំ** ប្រាសចាកធូលីគឺកិលេស

**១៣២.អសម្បុន្នំ** មិនកើតដោយបច្ច័យ

**១៣៣.បរមត្ថោ** ជាអារម្មណ៍នៃញាណដ៏ខ្ពង់ខ្ពស់

**១៣៤.និរាមិសំ** ប្រាស់ចាកអាមិស

**១៣៥.អប្បច្ចយា** មិនមានបច្ច័យក្នុងការកើតនិងតាំងនៅ

**១៣៦.បដិសោតំ** បញ្ច្រាស់សង្សារវដ្ត

**១៣៧.នេក្ខម្មំ** ចេញចាកសង្ខារធម៌

**១៣៨.បរមសច្ចំ** ជាអរិយសច្ចៈដ៏ប្រសើរ

**១៣៩.និព្វានសម្បត្តិ** សភាវៈក្រៃលែងជាងសម្បត្តិដទៃ

**១៤០.សារោ** ជាធម៌មានខ្លឹមសារ

**១៤១.សង្ខារូបសមោ** សភាវៈស្ងប់រម្ងាប់សង្ខារទាំងពួង

**១៤២.អសំកិលិដ្ឋំ** សភាវៈដែលមិនមានសេចក្តីសៅហ្មង

**១៤៣.ឆម្មោ** សភាវៈដែលទ្រទ្រង់ទុកនូវអ្នកបន្លុះមិនឱ្យកើតក្នុងវដ្តៈ។

## និព្វាននៅឯណា?

**និព្វានគ្មានកន្លែង គ្មានភព ក្នុងគម្ពីរទាំងឡាយពោលថា៖**

១.**និព្វាន** ជាដែនស្ងប់ ជាទីគ្មានទុក្ខ រលត់សង្ខារ រម្លាយអវិជ្ជា

២.**និព្វាន** ជាគ្រឿងឧបករណ៍ ជាធម្មជាតិអស់សកលកិលេស

៣.**និព្វាន** នៅគ្រប់កន្លែង

៤.**និព្វាន** ជាចំណុចសូន្យឧបាទាន

៥.**និព្វាន** ជាផលនៃការអស់កិលេស។

## និព្វានប្រៀបដោយលក្ខណៈ របស់អាកាស ១០ ប្រការ

១.**ន ជីយតិ** មិនចាស់ មិនគ្រាំគ្រា

២.ន **មីយតិ** មិនស្លាប់ គឺមិនសូន្យ

៣.ន **ចវតិ** មិនចុតិ គឺមិនវិនាសទៅណា

៤.ន **ឧប្បជ្ជតិ** មិនកើតគឺ មិនវិលកើតវិលស្លាប់

៥.**អប្បសយ្ហំ** មិនមានអ្នកគម្រាមកំហែង

៦.**អចោរគហណីយំ** ចោរមិនអាចបៀតបៀន

៧.**អនិស្សិតំ** មិនមានទីអាស្រ័យ

៨.**វិហង្គគមនំ** ក្រៅពីអ្នកមានឫទ្ធិមិនអាចអ្នកណានៅបាន

៩.**និរាវរណំ** មិនមានអ្វីនឹងរារាំង

១០.**អនន្តំ** មិនមានទីបំផុត។ (ឃ្លាំងបរិយត្តិភាគ២)

## អ្នករចនាក្រប

-សាមណេរជោតិវីរិយោ **យ៉ាវ ឡូច់ឌី**

## អ្នកពិនិត្យ

១.ភិក្ខុបធានជ្ជោតោ **ម៉ាន់ សុភាព**

២.ភិក្ខុសាសនរក្ខិតោ **សុខ ចន្ថា**

៣.ភិក្ខុវីរិយឆន្ទោ **ម៉ៅ មី**

៤.សាមណេរ កុលវឌ្ឍនោ **ខេង រ៉ាឃិត**

៥.សាមណេរ **ឆាន់ សុភ័ក្រ្ត**

៦.សាមណេរ **សេង ភារុណា**

៧.សាមណេរ **ធន់ សុធឿន**

# ឯកសារពិគ្រោះ

១.បរិច្ឆេទទី ៦ រូបបរមត្ថ

២.វចនានុក្រមសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួន **ណាត**

៣.សទ្ទានុក្រមព្រះពុទ្ធសាសនា

៥. អភិធម្មត្ថវិភាវនីដីកា

៦.បិដកភាគ ៣០ (ឥន្ទកសូត្រ)

៧.វិបស្សនាន័យភាគ ៣

៨.ព្រះរាជបណ្ណាល័យ បោះពុម្ពលើកទី២ ព្រះត្រៃបិដក បាលី និងប្រែជាភាសាខ្មែរ សុត្តន្តបិដកភាគ៣០ ភ្នំពេញ

៩.បដិកភាគ ៦

១០.បិដកភាគ ២៣

១១.ឃ្លាំងបរិយត្តិភាគ ២

១២.បរមត្ថទីបនី

១៣. A Manual of Abhidhamma By Narada Maha Thera, 1979

១៤.A Comprehensive Manual of Abhidhamma by Bhikkhu Bodhi, Reprinted 2010